សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

Université Royale de Droit et des Sciences Économiques

Royal University of Law and Economics

**សារណាបញ្ចប់ការសិក្សា**

# សន្តិកម្មតាមមតកសាសន៍នៅកម្ពុជា

ស្រាវជ្រាវចាប់ពីថ្ងៃទី៨ ខែមេសា ឆ្នាំ២០២៤ ដល់ថ្ងៃទី១០ ខែសីហា ឆ្នាំ២០២៤

ស្រាវជ្រាវដោយ

និស្សិតឈ្មោះ៖ **លោក ចាន ជីឃុន**

**កញ្ញា ហម គីមហ្លិក**

ណែនាំដោយ

សាស្ត្រាចារ្យ **បណ្ឌិត ហាប់ ផល្លី**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី២៤

ឆ្នាំចូលសិក្សា ២០២០

ឆ្នាំសរសេរសារណា ២០២៤

# **សេចក្តីថ្លែងអំណរគុណ**

យើងខ្ញុំឈ្មោះ បាទ ជីយុន និង ហម គីមហ៊្គិក ជានិស្សិតឆ្នាំទី៤ ថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ ជំនាន់ទី២៤ ក្រុមL4A2 នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។

**សូមគោរពប្រតិបត្តិ និងសូមសំដែងនូវកតញ្ញូតាធម៌យ៉ាងជ្រាលជ្រៅជូនចំពោះ**

**លោកឪពុក និងអ្នកម្តាយ** ដែលលោកអ្នកមានគុណទាំងទ្វេបានផ្តល់កំណើតដល់កូន និងបានខិតខំទាំងកម្លាំងកាយចិត្តក្នុងការចិញ្ចឹមបីបាច់ថែរក្សាអប់រំទូន្មានប្រៀនប្រដៅកូនទាំងយប់ទាំងថ្ងៃដោយមិនខ្លាចនឿយហត់ ព្រមទាំងបានធ្វើការឧបត្ថម្ភគាំទ្រទាំងផ្នែកស្មារតី សម្ភារៈ និងធនធានតាំងពីយើងខ្ញុំចាប់កំណើតរហូតដល់ធំពេញវ័យ ដើម្បីឱ្យយើងខ្ញុំបានសិក្សារៀនសូត្រ អប់រំឱ្យប្រព្រឹត្តអំពើល្អ និងបានជំរុញលើកទឹកចិត្តឱ្យយើងខ្ញុំបានចូលសិក្សារៀនសូត្រក្រេបជញ្ជក់ចំណេះដឹងតាំងពីកម្រិតថ្នាក់មូលដ្ឋាន រហូតដល់ពេលបច្ចុប្បន្ន។

**សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជូនចំពោះ**

ឯកឧត្តម សាកលវិទ្យាធិការ សាកលវិទ្យាធិការរង ព្រឹទ្ធបុរស សាស្ត្រាចារ្យ និងបុគ្គលិកទាំងអស់នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចដែលបានដឹកនាំគ្រប់គ្រងគ្រប់ផ្នែកយ៉ាងយកចិត្តទុកដាក់ និងបានខិតខំប្រឹងប្រែងអស់ពីកម្លាំងកាយចិត្ត ព្រមទាំងពេលវេលាដ៏មានតម្លៃក្នុងការបង្ហាត់បង្រៀនដល់យើងខ្ញុំទាំងពីរ។

លោកសាស្ត្រាចារ្យ បណ្ឌិត **ហាច់ ផល្លី** ជាសាស្ត្រាចារ្យ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានបង្ហាត់បង្រៀនដល់យើងខ្ញុំ។ ជាពិសេស លោកសាស្ត្រាចារ្យបានចំណាយពេលវេលាដ៏មានតម្លៃ របស់លោកក្នុងការពន្យល់ណែនាំ ចង្អុលបង្ហាញ ផ្តល់ឯកសារជាមួយបទពិសោធន៍ និងផ្តល់ជាគំនិតល្អក្នុងការសរសេរសារណានេះព្រមទាំងធ្វើការកែប្រែកំហុសឆ្គងរបស់យើងខ្ញុំ ដើម្បីធានាក្នុងការទទួលបាននូវសមិទ្ធផលមួយប្រកបដោយគុណភាព។

ជាទីបញ្ចប់ យើងខ្ញុំសូមគោរពជូនពរ និងសូមលើកហត្ថាទាំងទ្វេបួងសួងដល់ទេវតាដែលថែរក្សាព្រះរាជាណាចក្រកម្ពុជា និងបារមីវត្ថុស័ក្តិសិទ្ធិទាំងពួងនៅលើលោក សូមជួយអភិបាលថែរក្សាការពារ លោកអ្នកមានគុណទាំងទ្វេ ឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការរង ព្រឹទ្ធបុរស សាស្ត្រាចារ្យ និងបុគ្គលិកទាំងអស់នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រនិងវិទ្យាសាស្ត្រសេដ្ឋកិច្ចព្រមទាំងលោកសាស្ត្រាចារ្យបណ្ឌិត **ហាច់ ផល្លី** ឱ្យជួបប្រទះតែសេចក្តីសុខ សុខភាពល្អ សុភមង្គល ជោគជ័យគ្រប់ភារកិច្ច និងពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

ដោយឆ្លងតាមការសិក្សា និងស្វែងយល់អំពីទ្រឹស្តីនៅថ្នាក់បរិញ្ញាបត្រផ្នែកនីតិសាស្រ្តនៅ សាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច អស់រយៈពេល ៤ឆ្នាំកន្លងមក បានជួយជម្រុញក៏ដូចជាផ្តល់ឱកាសឱ្យយើងខ្ញុំ សម្រេចចិត្តក្នុងការសិក្សាស្រាវជ្រាវ និងចងក្រងសរសេរនូវអត្ថបទសារណានេះឡើងដែលមានចំណងជើងថា **សន្តតិកម្មតាមមតកសាសន៍នៅកម្ពុជា** ដើម្បីជាស្នាដៃ ជូនដល់សាកលវិទ្យាល័យ និងដើម្បីទុកតម្កល់នៃការសិក្សារបស់យើងខ្ញុំផងដែរ។ តាមរយៈស្នាដៃនេះក៏ជាឯកសារជំនួយមួយផ្នែកដល់មិត្តនិស្សិត អ្នកសិក្សាស្រាវជ្រាវ និងសាធារណជនគ្រប់មជ្ឈដ្ឋាន ដែលមានបំណងចង់សិក្សាបន្ថែមអាចយកទៅសិក្សាបន្ថែមផងដែរ។

កិច្ចការស្រាវជ្រាវនេះ ចងក្រងឡើងក្នុងគោលបំណងដើម្បីបង្ហាញអំពីខ្លឹមសារសំខាន់ៗ ក៏ដូចជា ការធ្វើសន្តតិកម្មតាមរយៈមតកសាសន៍ និងលក្ខខណ្ឌផ្សេងៗក្នុងការអនុវត្តនាពេលបច្ចុប្បន្នក្នុងផ្នែកនីតិរដ្ឋប្បវេណីដែលបានផ្តោតសំខាន់លើការធ្វើមតកសាសន៍ដោយមតកជន។ ជាងនេះទៅទៀតនៅក្នុងខ្លឹមសារក៏បានចង្អុលបង្ហាញអំពីនីតិវិធីលក្ខខណ្ឌនីមួយៗ ក៏ដូចជាបង្ហាញពីមាត្រានៃច្បាប់នានាដែលពាក់ព័ន្ធព្រមទាំងភ្ជាប់មកនូវឧទាហរណ៍មួយចំនួនផងដែរ។ ទន្ទឹមគ្នានេះនៅក្នុងការបកស្រាយក៏មានបញ្ហាមួយចំនួនដែលបានធ្វើឱ្យរាំងស្ទះដល់ការអនុវត្តនីតិវិធីជាក់ស្តែងធ្វើឱ្យមានការលំបាកក្នុងការស្វែងយល់ដោយហេតុក្រមរដ្ឋប្បវេណីនៅមានប្រភព និងឫសគល់ចេញពីការអនុវត្តក្នុងករណីប្រទេសជប៉ុន។ ជាងនេះទៀតសោត ការលើកយកប្រធានបទ សន្តតិកម្មតាមមតកសាសន៍ មកបកស្រាយគឺផ្អែកទៅតាមក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា រួមទាំងបទប្បញ្ញត្តិផ្សេងៗដែលជាមែកធាង និងការពាក់ព័ន្ធនៅក្នុងការអនុវត្តសន្តតិកម្មតាមមតកសាសន៍នេះ។

ជាចុងបញ្ចប់ ដោយសារតែចំណេះដឹងក្នុងការស្រាវជ្រាវនៅមានកម្រិត និងបទពិសោធន៍មានតិចតួចនៅឡើយ ទោះបីជាយើងខ្ញុំបានខិតខំប្រឹងប្រែង និងព្យាយាមស្រាវជ្រាវយ៉ាងណាក៏ដោយ ក៏សារណានេះនៅតែមានចំណុចខ្វះខាតដោយអចេតនានៅត្រង់ចំណុចណាមួយ។ ហេតុដូចនេះ យើងខ្ញុំសូមធ្វើការអភ័យទោសជាមុននូវរាល់កំហុសឆ្គងដោយអចេតនា និងសូមអរគុណយ៉ាងជ្រាលជ្រៅចំពោះ មតិយោបល់ ការរិះគន់ក្នុងន័យស្ថាបនាពីសំណាក់សាស្រ្តាចារ្យ រៀមច្បង មិត្តនិស្សិតទាំងអស់គឺជាអ្វីដែលមិនអាចខ្វះបានក្នុងគោលបំណង ជួយកែលម្អដើម្បីឱ្យសារណានេះមានភាពល្អប្រសើរឡើងបន្ថែមទៀតក្នុងការស្រាវជ្រាវលើប្រធានបទមួយនេះ។

# មាតិកា

ទំព័រ

**សេចក្ដីថ្លែងអំណរគុណ**

**អារម្ភកថា**

**បញ្ជីតារាង**

**សេចក្ដីផ្ដើម**.......... ១

១. បុព្វហេតុនៃការស្រាវជ្រាវ.......... ១

២. ចំណោទបញ្ហានៃការស្រាវជ្រាវ.......... ១

៣. គោលបំណងនៃការសិក្សាស្រាវជ្រាវ.......... ១

៤. ដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ.......... ២

៥. សារៈសំខាន់នៃការសិក្សាស្រាវជ្រាវ.......... ២

៦. វិធីសាស្ត្រនៃការសិក្សាស្រាវជ្រាវ.......... ២

៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ.......... ៣

**ជំពូកទី១**

**ទិដ្ឋភាពទូទៅនៃសន្តតិកម្ម**

**១.១ ការវិវត្តគតិយុត្តនៃរបបសន្តតិកម្មនៅកម្ពុជា**.......... ៤

១.១.១ របបសន្តតិកម្មមុនឆ្នាំ១៩៧៥.......... ៤

១.១.២ របបសន្តតិកម្មចាប់ពីថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១១.......... ៦

**១.២ ស្ថានភាពទូទៅនៃសន្តតិកម្ម**.......... ៨

១.២.១ កម្មវត្ថុនិងប្រភេទនៃសន្តតិកម្ម.......... ៨

១.២.២ លក្ខខណ្ឌក្នុងការបង្កើតមតកសាសន៍.......... ១០

**ជំពូកទី២**

**ការអនុវត្តសន្តតិកម្មនៅកម្ពុជា**

**២.១ ដំណើរការក្នុងការប្រតិបត្តិមតកសាសន៍**.......... ១៦

២.១.១ ការបែងចែកតាមមតកសាសន៍.......... ១៦

២.១.២ ការស្រុះស្រួលគ្នាក្នុងការបែងចែកមត៌ក.......... ១៧

**២.២ ភាពស្មុគស្មាញក្នុងការបែងចែកមត៌ក**.......... ១៨

២.២.១ ការមិនអនុវត្តតាមមតកសាសន៍.......... ១៩

២.២.១.១ មតកសាសន៍ដែលខុសទម្រង់....................................................... ១៩
២.២.១.២ មតកសាសន៍ដែលបង្កើតដោយបុគ្គលខ្វះសមត្ថភាព.......................... ២០
២.២.២ ការប៉ះពាល់ដល់ផលប្រយោជន៍សន្តតិជន....................................................... ២២
២.២.២.១ ការជំទាស់របស់សន្តតិជន ពីតុល្យភាពនៃការបែងចែក.......................... ២២
២.២.២.២ ការបែងចែកអច្ច័យទានឱ្យតតិយជន ដែលប៉ះពាល់ដល់សន្តតិជន.......... ២៥

**ជំពូកទី៣**

**បញ្ហាប្រឈមនៃសន្តតិកម្មតាមមតកសាសន៍**

**៣.១ កង្វះការយល់ដឹងស៊ីជម្រៅលើសន្តតិកម្មតាមមតកសាសន៍របស់អ្នកវិជ្ជាជីវៈ**...២៧
**៣.២ កង្វះការយល់ដឹងរបស់ប្រជាជនអំពីសន្តតិកម្មតាមមតកសាសន៍**.................... ៣១
**៣.៣ ការបន្តអនុវត្តមតកសាសន៍តាមទម្លាប់**........................................................... ៣៣
**សេចក្តីសន្និដ្ឋាន**........................................................................................................ ៣៥
**អនុសាសន៍**............................................................................................................... ៣៧
**គន្ថនិទ្ទេស**

# បញ្ជីតារាង

**ទំព័រ**

តារាង១៖ វត្តមាននៃច្បាប់គ្រប់គ្រងប្រព័ន្ធសន្តតិកម្មនៅកម្ពុជា........ ៧
តារាង២៖ អត្ថន័យនៃសន្តតិកម្មរបស់ច្បាប់ផ្សេងៗដែលពាក់ព័ន្ធនៅកម្ពុជា........ ៧
តារាង៣៖ ប្រភេទនៃសន្តតិកម្មនៅកម្ពុជា........ ៩
តារាង៤៖ លំដាប់នៃសន្តតិជន........ ៩
តារាង៥៖ ទម្រង់នៃមតកសាសន៍........ ១០
តារាង៦៖ ប្រភេទ និងលក្ខខណ្ឌផ្សេងៗនៃទម្រង់មតកសាសន៍ពិសេស........ ១២
តារាង៧៖ សមត្ថភាពក្នុងការធ្វើមតកសាសន៍........ ២១
តារាង៨៖ ដំណាក់កាលនៃការគណនាភាគបម្រុង........ ២៣
តារាង៩៖ រូបមន្តនៃការគណនាទ្រព្យសម្បត្តិជាមូលដ្ឋាន........ ២៤
តារាង១០៖ ប្រភេទនៃអច្ច័យទាន........ ២៦
តារាង១១៖ ដំណាក់កាលមុនការចុះបញ្ជី........ ២៩
តារាង១២៖ អ្នកមានសិទ្ធិចុះបញ្ជីនិងកន្លែងដាក់ពាក្យស្នើសុំ........ ៣០
តារាង១៣៖ ដំណាក់កាលនៃការចុះបញ្ជី........ ៣១

# សេចក្តីផ្តើម

# សេចក្តីផ្តើម

## ១. មូលហេតុនៃការស្រាវជ្រាវ

ប្រទេសកម្ពុជា គឺជាប្រទេសមួយដែលរីកចម្រើននិងកំពុងតែដំណើរការទៅមុខនៅគ្រប់វិស័យ មិនថាវិស័យកសិកម្ម ឧស្សាហកម្ម និងវិស័យផ្សេងៗទៀតក្រោមជំនួយ និងសហប្រតិបត្តិការពី វិនិយោគិនក្នុង និងក្រៅប្រទេស។ ជាក់ស្តែងទោះបីជា វិស័យនានានឹងកំពុងបោះជំហានទៅមុខក៏ដោយ ប៉ុន្តែហាក់បីដូចជាមានបញ្ហានានាកើតឡើងផងដែរ។ បើក្រឡេកមកមើលវិស័យច្បាប់ឃើញថា បញ្ហាខ្វះចន្លោះ និងភាពស្មុគស្មាញក៏ឃើញមានវត្តមានជាច្រើនករណីដែលបង្កើតបានជាភាពលំបាកដល់ប្រជាពលរដ្ឋផងដែរ។ ក្នុងនោះបញ្ហាដែលទាក់ទងទៅនឹងការបែងចែកមត៌កក៏ជាប្រធានបទមួយពេញនិយមនឹងឮជាញឹកញាប់នៅក្នុងប្រទេសកម្ពុជា។

ជាគោលការណ៍ ការបែងចែកមត៌កទៅឱ្យអ្នកជំនាន់ក្រោយគឺជាប្រធានបទ និងកិច្ចពិភាក្សាមួយដែលស្មុគស្មាញនិងពិបាកក្នុងការបកស្រាយនាពេលបច្ចុប្បន្ន។ ការបែងចែកទ្រព្យសម្បត្តិនេះមានវត្តមានតាំងពីយូរលង់ណាស់មកហើយតាំងពីសម័យបុរាណមកម៉្លេះ។

## ២. ចំណោទបញ្ហានៃការស្រាវជ្រាវ

ផ្អែកទៅតាមការលើកឡើង អំពីខ្លឹមសារខ្លះៗនៅចំណុចទី១ខាងលើអំពីលក្ខណៈទូទៅនៃសន្តតិកម្មហើយការសិក្សាស្រាវជ្រាវនៅក្នុងសារណានេះ គឺផ្តោតសំខាន់ខ្លាំងទៅលើសន្តតិកម្មតាមមតកសាសន៍ផងដែរ។ ប៉ុន្តែអ្វីដែលគួរយល់ដឹងនិងស្វែងយល់បន្ថែមនោះគឺប្រសិនបើមានការបែងចែកមត៌កតាមរយៈមតកសាសន៍៖ តើទ្រព្យទាំងនោះនឹងត្រូវបែងចែកយ៉ាងដូចម្តេច? តើអ្នកណាខ្លះមានសិទ្ធិទទួលបានទ្រព្យសម្បត្តិពីអ្នកស្លាប់? តើអាចបែងចែកទ្រព្យដែលជាមត៌កនោះបានតែលើសន្តតិជនទេ ឬអាចបែងចែកឱ្យតតិយជនក៏បានដែរ?

## ៣. គោលបំណងនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវ និងការរៀបចំតាក់តែងសារណានេះធ្វើឡើងក្នុងគោលបំណងចែករំលែកចំណេះដឹងមូលដ្ឋានមួយសម្រាប់មិត្តអ្នកអានទាំងអស់ ក្នុងការពិចារណាទៅលើបញ្ហាពាក់ព័ន្ធនឹងការបែងចែកមត៌កតាមរយៈមតកសាសន៍ភាពស្មុគស្មាញនៃការអនុវត្តប្រចាំថ្ងៃនៅក្នុងប្រទេសកម្ពុជា បញ្ហាប្រឈមដែលកើតឡើងជាញឹកញាប់ និងដំណោះស្រាយដែលអាចនឹងកាត់បន្ថយការកើនឡើងនូវចំណុចអវិជ្ជមាននៅថ្ងៃខាងមុខ។ ជាពិសេសប្រធានបទមួយនេះពិតជាមានសារៈសំខាន់ណាស់សម្រាប់ និស្សិតដែលសិក្សាច្បាប់កំពុងស្វែងរកបន្ថែមនូវចំណេះដឹងទាក់ទងនឹងសន្តតិកម្មនៅកម្ពុជា។ អ្វីដែលសំខាន់នោះ គឺដើម្បីឱ្យប្រជាពលរដ្ឋទាំងអស់មានការយល់ដឹងពីមូលដ្ឋានគ្រឹះបន្ថែមអំពីការតាក់តែងមតកសាសន៍ ឱ្យត្រឹមត្រូវតាមទម្រង់ដើម្បីអាចអនុវត្តបាននៅពេលដែលមតកជនទទួលមរណភាពទៅដោយជៀសវាងពីការលុបចោល និងមិនមានអានុភាពនៃមតកសាសន៍ ដែលធ្វើឱ្យបាត់បង់ផលប្រយោជន៍ និងឆន្ទៈរបស់មតកជននៅពេលខាងមុខ។

## ៤. ដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ

ចំពោះប្រធានបទ សន្តតិកម្មតាមមតកសាសន៍នៅកម្ពុជា មានវិសាលភាពគ្របដណ្តប់ទៅលើការអនុវត្តជាក់ស្តែង និងបញ្ហាដែលកើតឡើងក្នុងតថភាពសង្គមបច្ចុប្បន្ន។ ចំណុចសំខាន់នឹងយកមករៀបចំចងក្រងឡើងរួមមាន៖

- ស្វែងយល់ពីស្ថានភាពទូទៅនៃសន្តតិកម្មជាគំនិតចម្បង និងច្បាប់គ្រប់គ្រងរបបសន្តតិកម្មនៃព្រះរាជាណាចក្រកម្ពុជា។
- ការអនុវត្តសន្តតិកម្ម ចាប់ពីមតកជនទទួលមរណភាពរហូតដល់ការបែងចែកមត៌ក និងបញ្ហាដែលកើតឡើង ក្នុងអំឡុងពេលបែងចែកមត៌ក។
- ស្វែងយល់ពីភាពខ្វះចន្លោះដែលកើតឡើងដោយសារការយល់ដឹងអំពីបញ្ហាសន្តតិកម្មនៅមានកម្រិត ពីសំណាក់ប្រជាពលរដ្ឋ និងភាពចន្លោះប្រហោង នៃប្រព័ន្ធច្បាប់ដែលធ្វើឱ្យបាត់បង់ផលប្រយោជន៍ដល់ប្រជាពលរដ្ឋ។

## ៥. សារៈសំខាន់នៃការស្រាវជ្រាវ

ការសិក្សាចងក្រងប្រធានបទ សន្តតិកម្មតាមមតកសាសន៍ ផ្តោតសំខាន់ទៅលើខ្លឹមសារដែលជាផលប្រយោជន៍ជូនដល់មិត្តអ្នកអាន និងនិស្សិតទាំងអស់ដូចជា៖

- យល់ដឹងអំពីចំណេះដឹងទូទៅទាក់ទងនឹងសន្តតិកម្មតាមមតកសាសន៍
- អាចទទួលបាននូវព័ត៌មានជុំវិញប្រធានបទនេះ ឯកសារជាមេរៀនច្បាប់និងបទដ្ឋានគតិយុត្តផ្សេងៗពាក់ព័ន្ធទៅនឹងប្រធានបទ
- អាចដឹងអំពីបញ្ហាដែលកើតឡើងជាញឹកញាប់ ដែលធ្វើឱ្យមិត្តអ្នកអានអាច ជៀសវាងពីការកើតឡើងនូវបញ្ហាអវិជ្ជមានណាមួយនៅថ្ងៃអនាគត
- អ្វីដែលពិសេសនោះគឺជាផលប្រយោជន៍ដ៏មហាអស្ចារ្យដើម្បីបានបន្សល់ទុកជាស្នាដៃសម្រាប់សិស្សនិស្សិតក៏ដូចជាមិត្តអ្នកអាននិងអ្នកសិក្សាស្រាវជ្រាវទាំងឡាយដើម្បីបានធ្វើជាមូលដ្ឋានក្នុងការស្វែងយល់ និងទទួលបានចំណេះដឹងបន្ថែម។

## ៦. វិធីសាស្ត្រនៃការសិក្សាស្រាវជ្រាវ

ដើម្បីធ្វើឱ្យបានសម្រេចនូវកិច្ចការស្រាវជ្រាវនេះឱ្យមានភាពល្អប្រសើរ សារណានេះនិងផ្អែកជាចម្បងទៅលើឯកសារមេរៀនជាច្រើនក្នុងនោះរួមមាន ច្បាប់ លិខិតបទដ្ឋានគតិយុត្តផ្សេងៗដែលពាក់ព័ន្ធទៅនឹងប្រធានបទមិនតែប៉ុណ្ណោះក៏មានកិច្ចសម្ភាសផ្សេងៗទៀតចូលរួមពីសំណាក់អ្នកជំនាញ និងសាស្ត្រាចារ្យដែលបង្រៀននៅសាកលវិទ្យាល័យ។ បន្ទាប់ពីបានធ្វើការស្វែងរកព័ត៌មានផ្សេងៗរួចធ្វើការពិភាក្សា អំពីស្ថានភាពទាក់ទងទៅនឹងសន្តតិកម្មតាមមតកសាសន៍នៅប្រទេសកម្ពុជា ការអនុវត្តផ្សេងៗព្រមទាំងផលវិបាកក្នុងការរាំងស្ទះដែលឃើញមានក្នុងការអនុ

វត្តប្រចាំថ្ងៃ នៃព្រះរាជាណាចក្រកម្ពុជា និងក្រោយមកនឹងធ្វើការបកស្រាយអំពី ទស្សនៈការយល់ឃើញចំពោះបញ្ហាទាំងនោះ និងបញ្ចេញមតិផ្ទាល់ខ្លួន។

## ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

សារណានេះចែកចេញជា៣ជំពូក។ ជំពូកទី១ អំពីទិដ្ឋភាពទូទៅនៃសន្តតិកម្មតាមមតកសាសន៍ដែលអនុវត្តនៅប្រទេសកម្ពុជា ព្រមទាំងច្បាប់នានាដែលគ្រប់គ្រងរបបសន្តតិកម្មតាំងពីដើម និងស្ថានភាពទូទៅនៃសន្តតិកម្មដែលអនុវត្តក្នុងតថភាពសង្គមខ្មែរ។ រីឯ ជំពូកទី២ ពិភាក្សាអំពីដំណើរការក្នុងការប្រតិបត្តិមតកសាសន៍ និងភាពស្មុគស្មាញដែលកើតឡើងក្នុងការបែងចែកមត៌ក។ ចំណែកឯជំពូកទី៣ នឹងលើកឡើងពីបញ្ហានានាដែលកើតឡើងនាពេលចាប់ផ្តើមបែងចែកមត៌កតាមមតកសាសន៍ដោយកង្វះការយល់ដឹងពីសំណាក់អ្នកវិជ្ជាជីវៈ និងប្រជាពលរដ្ឋដែលប្រកាន់ខ្ជាប់ការអនុវត្តតាមទំនៀមទម្លាប់។

# ជំពូកទី ១

# ទិដ្ឋភាពទូទៅនៃសន្តិកម្ម

# ជំពូកទី១ ទិដ្ឋភាពទូទៅនៃសន្តតិកម្ម

## ១.១ ការវិវត្តគតិយុត្តនៃរបបសន្តតិកម្មនៅកម្ពុជា

### ១.១.១ របបសន្តតិកម្មមុនឆ្នាំ១៩៧៥

នៅប្រទេសកម្ពុជា របបសន្តតិកម្ម ត្រូវបានកកើតឡើងតាំងពីយូរលង់ណាស់មកហើយ ពោលគឺចាប់តាំងពីការកកើតដំបូង នៃប្រទេសកម្ពុជា។[1] ការបែងចែកមត៌កតាំងពីសម័យបុរាណ ត្រូវបានធ្វើឡើងតាមប្រពៃណីទំនៀមទម្លាប់ដែលបន្សល់ទុកតៗគ្នា។ ជាឧទាហរណ៍ ក្នុងអក្សរសិល្ប៍ខ្មែរក៏មានលើកមកខ្លះដែលអំពីការបែងចែកមត៌កទៅឱ្យអ្នកជំនាន់ក្រោយ ពិសេសក្នុងរឿងតេជោយ៉ត ដែលមានតេជោមាសគឺជាមេទ័ពខ្លាំងក្លាម្នាក់ដែលយកឈ្នះសត្រូវជាញឹកញាប់ថែមទាំងមានប្រាជ្ញាឈ្លាសវៃ។ តេជោមាសមានសិស្សមួយរូបដែលមានសមត្ថភាពខ្លាំងក្លាតែងតែទៅធ្វើសង្គ្រាមគ្រប់សមរភូមិនោះគឺតេជោយ៉ត លុះពេលដែលតេជោមាសទទួលមរណភាព តេជោយ៉តបានទទួលមុខតំណែងបន្តដែលជាមេទ័ពក្នុងការដឹកនាំសឹកសង្គ្រាម ដោយស្នងតំណែងពី តេជោមាស ដែលជាផ្នែកមួយនៃការស្នងមត៌កនៅសម័យនោះផងដែរ។[2]

ទោះបីជាមានការបង្ហាញតាមរយៈអក្សរសិល្ប៍ខ្មែរ អំពីការស្នងមត៌កពីបុព្វញាតិជំនាន់មុន មកអ្នកស្នងជំនាន់ក្រោយ ដែលអាចមានឋានៈមិនមែនជាកូនរបស់មតកជន។ ការអនុវត្តជាក់ស្តែងតាំងពីបុរាណមកមិនមានលក្ខណៈដូចនេះទេ។ ការបែងចែកមត៌ក គឺអនុវត្តតែលើទាយាទប៉ុណ្ណោះជាអ្នកមានសិទ្ធិក្នុងការទទួលបន្តចំណែកឯសហព័ទ្ធ នៅមិនទាន់មានឋានៈជាអ្នកមានសិទ្ធិទទួលស្នងមត៌កនៅឡើយ ឬចូលរួមក្នុងការបែងចែកមត៌កបានជាមួយនឹងទាយាទរបស់មតកជននោះទេ។[3] ការបែងចែកទ្រព្យដែលជាមត៌កបន្តទៅឱ្យទាយាទមានភាពលំអៀងមិនប្រក្រតីផងដែរទៅតាមសម័យកាលនីមួយៗ រវាងទាយាទដែលជាកូនប្រុសនិងទាយាទដែលជាកូនស្រី។ ទ្រព្យសម្បត្តិមួយភាគច្រើននឹងត្រូវធ្លាក់ទៅលើទាយាទដែលជាកូនប្រុសច្រើនជាង "ដោយសារការអនុវត្តនេះធ្វើឡើងតៗគ្នាពីដើមមកដោយគេមានទស្សនៈមួយគឺ ស្ត្រីបង្វិលចង្ក្រានមិនជុំ"[4] ដូច្នេះហើយតែងតែមានភាពលំអៀងទៅលើកូនប្រុសជាង។ ការអនុវត្តបែបលក្ខណៈប្រពៃណីជាញឹកញាប់តែងកើតជាបញ្ហាដោយសារភាពអយុត្តិធម៌ចំពោះទាយាទ ដែលមិនបានទទួលអ្វីសោះ ឬបានចំណែកមិនសមតុល្យពីបុព្វញាតិរបស់ខ្លួន ជាហេតុបង្កបានទៅជាទំនាស់ដែលអាចឈានដល់ការបែកបាក់គ្រួសារ និងសង្គម។

---

[1] អាដេម៉ារ ឡឺក្លែរ, *មជ្ឈមណ្ឌលឯកសារកម្ពុជា, ប្រវត្តិសាស្ត្រប្រទេសកម្ពុជា ចាប់តាំងពីសតវត្សរ៍ទី១ នៃគ្រិស្តសករាជរហូតមក* (ភ្នំពេញ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា, ២០០៥)។

[2] ទី ជីហួត, *រឿងតេជោយ៉ត,* បោះពុម្ពលើកទី២ (ភ្នំពេញ៖ ស្រី ប៊ុនដន, ២០០៥), ៩។

[3] ជួន ណាត, *វចនានុក្រមខ្មែរ* (ភ្នំពេញ៖ ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ, ១៩៦៨)។

[4] ម៉ែន សំអន, "វេទិកាផ្សព្វផ្សាយយេនឌ័រ" មជ្ឈមណ្ឌលកោះពេជ្រភ្នំពេញ នារសៀលថ្ងៃទី៩ ខែកុម្ភៈ ឆ្នាំ២០២០), https:/www.cpp.org.kh/details/181684 (ទស្សនាចុងក្រោយ ១២ សីហា ២០២៤)។

ការលេចឡើងនូវរបបបន្តវេន ឬស្នងមត៌កពីជំនាន់មួយទៅជំនាន់មួយទៀតហាក់ដូចជាមានវត្តមានជាយូរណាស់មកហើយ។ ចាប់តាំងពីសម័យចេនឡាមកម្ល៉េះដោយការបែងចែកមត៌កសម័យចេនឡា នៅពេលរៀបអាពាហ៍ពិពាហ៍កូនកម្លោះតែងតែទទួលបាននូវមត៌កពីឪពុកម្តាយរបស់ខ្លួន ដើម្បីរកផ្ទះរស់នៅផ្សេងៗដាច់ដោយឡែកហើយប្រសិនបើឪពុកម្តាយនោះស្លាប់មុនថ្ងៃអាពាហ៍ពិពាហ៍របស់កូនប្រុស ទ្រព្យជាមត៌កត្រូវបានផ្ទេរមកកូនទាំងអស់ ផ្ទុយមកវិញបើកូនប្រុសរៀបការមុនមរណភាពនៃឪពុកម្តាយវិញ មត៌កដែលនៅសល់ពីការចែកឱ្យកូនប្រុសដើម្បីរកផ្ទះរស់នៅដាច់ដោយឡែកនោះ នឹងក្លាយជាទ្រព្យសម្បត្តិរបស់រដ្ឋ។[5] ឯកសារប្រវត្តិសាស្ត្រក៏បានបញ្ជាក់យ៉ាងច្បាស់ផងដែរអំពីការបែងចែកទ្រព្យនៅក្នុងសម័យចេនឡា ដោយចំណែកនៃការទទួលបាននូវមត៌កគឺធ្វើឡើង តែកូនប្រុសប៉ុណ្ណោះមិនមានវត្តមានកូនស្រីនោះទេ។ តើនៅក្នុងសម័យចេនឡាទ្រព្យជាមត៌កពិតជាត្រូវបានបែងចែកឱ្យតែកូនប្រុសឬយ៉ាងណា? បើដូច្នេះមែន ការបែងចែកតាមទំនៀមទម្លាប់នេះពិតជាមានភាពអយុត្តិធម៌កើតឡើង។ ការបែងចែកមត៌កគឺជា ការផ្ទេរទ្រព្យសម្បត្តិពីមតកជនទៅឱ្យទាយាទប៉ុន្តែការអនុវត្តនេះមានភាពខុសប្លែកគ្នាតាមសម័យកាល យោងតាមឯកសាររបស់អ្នកសិក្សាស្រាវជ្រាវសរសេរប្រវត្តិសាស្ត្រចិនមួយរូបបានរកឃើញថា នៅពេលរៀបអាពាហ៍ពិពាហ៍ប្តីប្រពន្ធដែលជាទាយាទទើបរៀបការរួចនាំគ្នារស់នៅលើផ្ទះថ្មីដោយនាំយកកេរមត៌កខ្លះដែលឪពុកម្តាយចែកឱ្យ។ ពេលឪពុកម្តាយស្លាប់ទ្រព្យទាំងអស់នឹងត្រូវចែកម្តងទៀតស្មើជាមួយបងប្អូនបង្កើតបន្តដែលជាសន្តតិជន។[6] ដូច្នេះអត្ថន័យនៃការបែងចែកមត៌កនៅសម័យបុរាណ មិនមែនសំដៅដល់តែការបែងចែកមត៌កពេលមតកជនទទួលមរណភាពទេពោលគឺនៅពេលមតកជននៅរស់ក៏អាចបែងចែកបានដែរអាស្រ័យទៅលើទំនៀមទម្លាប់ប្រពៃណី នៅក្នុងសម័យកាលនីមួយៗ។

រហូតមកដល់ឆ្នាំ១៩២០ កម្ពុជាបានបង្កើតក្រមរដ្ឋប្បវេណីដំបូងគេដែលពេលនោះគឺស្ថិតនៅក្នុងឥទ្ធិពលនៃក្រមរដ្ឋប្បវេណីបារាំង [7] ហើយក៏ជាច្បាប់ដំបូងបានកំណត់អំពីលំដាប់សន្តតិជនដែលមានសិទ្ធិក្នុងការទទួលបានចំណែកមត៌កបន្សល់ពីបុព្វញាតិ និងនីតិវិធីផ្សេងៗស្តីអំពីការដោះស្រាយវិវាទដែលកើតឡើងទាក់ទងនឹងសន្តតិកម្ម។ ប្រភេទនៃសន្តតិកម្មនៅក្រមរដ្ឋប្បវេណីឆ្នាំ១៩២០នេះបានចែងជា២ប្រភេទ គឺសន្តតិកម្មមានបណ្តាំ និងសន្តតិកម្មឥតបណ្តាំ។ សន្តតិកម្មមានបណ្តាំ គឺជាការផ្ទេរទ្រព្យសម្បត្តិតាមឆន្ទៈរបស់ខ្មោច ចំណែកសន្តតិកម្មឥតបណ្តាំ គឺជាការផ្ទេរទ្រព្យសម្បត្តិតាមច្បាប់ចែង។[8] ក្រមរដ្ឋប្បវេណីឆ្នាំ១៩២០ បានបែងចែកទ្រព្យសម្បត្តិខុសពីសម័យបុរាណ ដែលជាការបែងចែកមត៌កធ្វើតាមទឹកចិត្តរបស់មតកជន ស្រឡាញ់អ្នកណាជាងគេប្រគល់ឱ្យអ្នកនោះច្រើនជាងគេ ចំណែកបុគ្គលដែលសន្តតិជនដទៃ ពេលខ្លះមិនទទួលបានមត៌កអ្វីសោះ។

---

[5] កើត រិទ្ធ និងផ្សេងទៀត, "សេចក្តីផ្តើមនៃនីតិកម្ពុជា" (ការិយាល័យស្រាវជ្រាវនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចភ្នំពេញ ២០០៥), ទំព័រ៥។

[6] ដូច១, ទំព័រ៤។

[7] ក្រមរដ្ឋប្បវេណីឆ្នាំ១៩២០, ប្រកាសឱ្យប្រើនៅថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ១៩២០ (ពីពេលនេះតទៅហៅថាក្រមរដ្ឋប្បវេណីឆ្នាំ១៩២០)។

[8] ក្រមរដ្ឋប្បវេណីឆ្នាំ១៩២០, មាត្រា៤៨៦។

ទោះបីជាមានការគ្រប់គ្រងល្អប្រសើរ នូវរបបសន្តតិកម្មដោយក្រមរដ្ឋប្បវេណីឆ្នាំ១៩២០ ក៏ពិតមែន របបសន្តតិកម្មទាំងមូលត្រូវបានរលាយ និងបាត់សូន្យឈឹងទៅវិញនៅឆ្នាំ១៩៧៥។ ភ្លើងសង្គ្រាមយ៉ាងឃោរឃៅនាសម័យកម្ពុជាប្រជាធិបតេយ្យ បានធ្វើឱ្យប្រទេសកម្ពុជាទាំងមូលបាត់បង់វត្តមាននូវច្បាប់នានារួមទាំងច្បាប់ទាំងឡាយណាគ្រប់គ្រងរបបសន្តតិកម្មផងដែរ។ នៅក្នុងរបបនេះ បានធ្វើឱ្យប្រជាពលរដ្ឋទាំងអស់មានភាពភ័យខ្លាចអាថ៌មទាំងធ្វើឱ្យហេដ្ឋារចនាសម្ព័ន្ធនៅក្នុងប្រទេសទទួលរងនូវការខូចខាតយ៉ាងធ្ងន់ធ្ងរ។ ការរស់នៅរបស់ប្រជាជនគ្រប់រូបត្រូវបានផ្លាស់ប្តូរមកជាគ្មានកម្មសិទ្ធិ ទ្រព្យសម្បត្តិត្រូវស្ថិតក្រោមការគ្រប់គ្រង និងជាកម្មសិទ្ធិរបស់អង្គការតែមួយគត់ ពោលគឺគ្មានទេកម្មសិទ្ធិឯកជននៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យនោះទេ។[9] ចាប់តាំងពីសម័យកម្ពុជាប្រជាធិបតេយ្យដួលរលំ របបសន្តតិកម្មបានក្លាយជាបញ្ហាស្មុគស្មាញនៅក្នុងសង្គម។ ក្រោយឆ្នាំ១៩៧៩ ច្បាប់នានាដែលគ្រប់គ្រងរបបសន្តតិកម្មមិនត្រូវបានទទួលស្គាល់ដោយរាជរដ្ឋាភិបាល ការអនុវត្តបែងចែកមត៌កត្រូវបានធ្វើឡើងដោយ ឆន្ទានុសិទ្ធិរបស់ចៅក្រមក្នុងការសម្រេចសេចក្តីអំពីចំណែកនិងវិធីក្នុងការបែងចែក។

**១.១.២ របបសន្តតិកម្មចាប់ពីថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១១**

ទោះបីជាប្រទេសកម្ពុជាទើបតែងើបពីភ្លើងសង្គ្រាម វិធានគតិយុត្តផ្សេងៗគ្រប់គ្រងរបបសន្តតិកម្មត្រូវបានបង្កើតឡើងនិងលេចវត្តមាននៅក្នុងប្រទេសវិញ។ ក្រោយពីការបំពេញបន្ថែមចន្លោះខ្វះខាតទៅលើច្បាប់ដែលមានវត្តមានស្រាប់ពីអតីតកាលកម្ពុជាបានកសាងប្រទេសរបស់ខ្លួនពីចំណុចសូន្យរហូតដល់បង្កើតបានសមិទ្ធផលមួយដែលធំធេង គឺក្រមរដ្ឋប្បវេណីថ្មីដែលបានលេចជារូបរាងឡើងនៅឆ្នាំ២០០៧ តាមរយៈជំនួយផ្នែកតាក់តែងច្បាប់ពីប្រទេសជប៉ុន និងត្រូវបានអនុវត្តពេញលេញថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១១ ដោយច្បាប់ស្តីពីការអនុវត្តក្រមមានចែងយ៉ាងច្បាស់ពីសញ្ញាណទូទៅ និងលក្ខខណ្ឌផ្សេងៗអំពីសន្តតិកម្មផងដែរ។ ក្រមរដ្ឋប្បវេណីថ្មីនេះបានឱ្យនិយមន័យ សន្តតិកម្មថា "ជាការផ្ទេរនូវសិទ្ធិ និងករណីយកិច្ចរបស់មតកជនទៅឱ្យសន្តតិជនម្នាក់ ឬច្រើននាក់តាមឆន្ទៈ ឬតាមច្បាប់"[10] ហើយសន្តតិកម្មមិនអាចចាប់ផ្តើមបានទេ ប្រសិនបើមតកជននៅមានជីវិតរស់នៅនៅឡើយទោះបីជាមតកជននោះបានធ្វើមតកសាសន៍រួចរាល់ហើយក៏ដោយ។ យ៉ាងណាមិញដើម្បីសម្រួលក្នុងករណីមតកជនបានបាត់ខ្លួនសន្តតិកម្មអាចចាប់ផ្តើមបានដែរ នៅពេលដែលមានសាលក្រមស្ថាពររបស់តុលាការដែលបានបញ្ជាក់អំពីការបាត់ខ្លួនរបស់មតកជននោះ។

---

[9] ហាប់ ផល្ញី, *នីតិទ្រព្យសម្បត្តិឯកជន៖ ករណីសិក្សានៅកម្ពុជា* (ភ្នំពេញ៖ Premium Advertising, ២០២១), ១។

[10] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, សទ្ទានុក្រមផ្នែករដ្ឋប្បវេណី, ២១ (ពីពេលនេះតទៅហៅថាក្រមរដ្ឋប្បវេណីឆ្នាំ២០០៧)។

តារាង១៖ វត្តមាននៃច្បាប់គ្រប់គ្រងប្រព័ន្ធសន្តតិកម្មនៅកម្ពុជា។[11]




ទោះបីជាប្រទេសកម្ពុជាមានច្បាប់ស្តីពីការបែងចែកមត៌ក និងរបបគ្រប់គ្រងរបបសន្តតិកម្ម តាមរយៈច្បាប់នានាពីសម័យមួយទៅសម័យមួយ ក៏ភាពយល់ដឹងនៃសន្តតិកម្មនេះចំពោះប្រជាពលរដ្ឋនៅមានកម្រិត។ ដែលការបន្តទ្រព្យសម្បត្តិទៅកូនចៅជំនាន់ក្រោយគឺ ធ្វើឡើងដោយផ្ទុយពីការណែនាំដោយច្បាប់។ នាពេលបច្ចុប្បន្ន ច្បាប់ដែលដឹកនាំ និងតម្រង់ទិសពីលក្ខខណ្ឌផ្សេងៗ និងការឱ្យនិយមន័យ នៃពាក្យថា សន្តតិកម្មក៏មានការខុសប្លែកគ្នាបន្តិចៗផងដែរ។

តារាង២៖ អត្ថន័យនៃសន្តតិកម្មរបស់ច្បាប់ផ្សេងៗដែលពាក់ព័ន្ធនៅកម្ពុជា[12]

| **ល.រ** | **ច្បាប់** | **អត្ថន័យនៃសន្តតិកម្ម** | **កម្មវត្ថុនៃសន្តតិកម្ម** |
|---|---|---|---|
| **១** | ច្បាប់ភូមិបាល, លេខ ១០០ក្រ, ១៣ តុលា ១៩៩២, មាត្រា១៧០ (១) និងសទ្ទានុក្រម | • សន្តតិកម្មគឺជាការផ្ទេរនូវបេតិកភណ្ឌនៃបុគ្គលណាម្នាក់ដែលស្លាប់ឱ្យទៅជនម្នាក់ទៀត ឬច្រើននាក់ដែលហៅថាទាយាទ ឬសន្តតិជន។ | បេតិកភណ្ឌ (ទ្រព្យសកម្ម និងបំណុល) នៃអ្នកស្លាប់ជាកម្មវត្ថុនៃសន្តតិកម្ម។ |

[11] ស៊ិន ច័ន្ទផល្លុន, "សន្តតិកម្ម គោលការណ៍ទូទៅ" (ឯកសារថតចម្លងវគ្គបណ្តុះបណ្តាលក្រមរដ្ឋប្បវេណី វគ្គ៥), ៤។

[12] ហាប់ ផល្លី, *នីតិទ្រព្យសម្បត្តិឯកជន៖ ករណីសិក្សានៅកម្ពុជា* (ភ្នំពេញ៖ Premium Advertising, ២០២១), ១៣៧។

| | | | |
|---|---|---|---|
| | | • ការបញ្ជូនតាមច្បាប់នូវទ្រព្យរបស់អ្នកស្លាប់ឱ្យទៅអ្នករស់។ មត៌ក ឬទ្រព្យរបស់ខ្មោចដែលត្រូវបានទៅទាយាទ | |
| ២ | ច្បាប់ភូមិបាល, លេខ នស/រកម/០៨០១/១៤, ៣០ សីហា ២០០១, សទ្ធានុក្រម | ការផ្ទេរតាមច្បាប់នូវទ្រព្យរបស់អ្នកស្លាប់ឱ្យទៅអ្នករស់។ មត៌ក ឬទ្រព្យរបស់ខ្មោចដែលត្រូវបានទៅទាយាទ (អ្នកបន្តមត៌ក)។ | ទ្រព្យជាកម្មវត្ថុនៃសន្តតិកម្ម។ |
| ៣ | ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០, ៨ ធ្នូ ២០០៧ សទ្ធានុក្រម | ការផ្ទេរនូវសិទ្ធិ និងករណីយកិច្ចរបស់មតកជនទៅឱ្យសន្តតិជនម្នាក់ ឬច្រើននាក់តាមឆន្ទៈ ឬតាមច្បាប់។ | សិទ្ធិ និងករណីយកិច្ចជាកម្មវត្ថុនៃសន្តតិកម្ម |

ច្បាប់ខាងលើនេះ គឺជាច្បាប់ពិសេសដែលបានលើកឡើងពី និយមន័យនៃសន្តតិកម្មតាមមជ្ឈដ្ឋាននីមួយៗ ទោះបីជាមានការបញ្ចេញនូវនិយមន័យពីច្បាប់នីមួយៗ តែឃើញមានការកំណត់សម្គាល់មានភាពប្រហាក់ប្រហែលគ្នាច្រើនទៅនិយមន័យគ្រាន់តែមានការប្រើប្រាស់ពាក្យពេចន៍ផ្សេងពីគ្នា។

## ១.២ ស្ថានភាពទូទៅនៃសន្តតិកម្ម

### ១.២.១ កម្មវត្ថុ និងប្រភេទនៃសន្តតិកម្ម

សន្តតិកម្ម តាមន័យទូទៅ សំដៅលើដំណើរការផ្លូវច្បាប់ ដែលសិទ្ធិ និងកាតព្វកិច្ចរបស់បុគ្គលម្នាក់ដែលជាមតកជន ត្រូវបានផ្ទេរទៅឱ្យអ្នកផ្សេងទៀតដែលជាទាយាទឬហៅម្យ៉ាងទៀតថាជាសន្តតិជន នៅពេលមតកជនស្លាប់។[13] ទម្រង់សំខាន់ពីរនៃសន្តតិកម្មមាន២ប្រភេទ ប្រភេទទី១ គឺជាការបែងចែកទ្រព្យជាមត៌កតាមផ្លូវច្បាប់ដែលមានចែងរួចជាស្រេច នៅពេលអវត្តមានឆន្ទៈឬមិនមានការផ្តែផ្តាំណាមួយធ្វើឡើងដោយមតកជនអំពីខ្លឹមសារនៃការបែងចែកមត៌ក[14] និងប្រភេទទី២ គឺសន្តតិកម្មតាមមតកសាសន៍ដែលសំដៅលើប្រភេទសន្តតិកម្មម្យ៉ាងដែលមតកជន បានសរសេរបន្សល់ទុកដើម្បីបង្ហាញនូវឆន្ទៈក្នុងការបែងចែកមត៌ករបស់ខ្លួនទៅឱ្យសន្តតិជនជំនាន់ក្រោយ។[15]

[13] គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា, ព្រឹត្តិបត្រមេធាវី, លេខ១៣ (២០១៧), ២៨។
[14] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា១១៤៥(២)។
[15] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា១១៤៥(២)។

តារាង៣៖ ប្រភេទនៃសន្តតិកម្មនៅកម្ពុជា

| សន្តតិកម្មតាមច្បាប់[16] | សន្តតិកម្មតាមមតកសាសន៍[17] |
|---|---|
| ក្នុងករណីមិនមានមតកសាសន៍ បន្សល់ទុកពីមតកជនមុនទទួលមរណភាព។ | មានបន្សល់ទុកមតកសាសន៍ ដែលបង្ហាញពីឆន្ទៈរបស់មតកជនមុនទទួលមរណភាព។ |

អ្វីដែលគួរឱ្យកត់សម្គាល់ និងចាប់អារម្មណ៍នោះគឺ សន្តតិកម្មតាមរបៀបទីមួយវិញដែលជាសន្តតិកម្មតាមច្បាប់ ការផ្ទេរមត៌កទៅឱ្យសន្តតិជនគឺផ្អែកទៅលើឋានៈបុគ្គល និងលំដាប់ថ្នាក់នៃសន្តតិជនដែលបានចែងមកយ៉ាងច្បាស់ក្នុងច្បាប់ ហើយលំដាប់ថ្នាក់នៃសន្តតិជននេះក៏អាចប្រែប្រួលយ៉ាងទូលំទូលាយទៅតាមយុត្តាធិការនៃប្រទេសនីមួយៗ។ ជាទូទៅការធ្វើតាមឋានានុក្រមនៃអ្នកស្នងមត៌ក ជាធម្មតា សហព័ទ្ធ និងកូនៗរបស់អ្នកស្លាប់គឺជាមនុស្សដំបូងគេក្នុងការទទួលមត៌កនេះ បន្ទាប់មកសមាជិកគ្រួសារផ្សេងៗទៀតដូចជាឪពុកម្ដាយ និងបងប្អូនបង្កើតរបស់អ្នកស្លាប់។[18] ពេលខ្លះទ្រព្យសម្បត្តិអាចធ្លាក់លើបុគ្គលផ្សេងដែលមិនមែនជាញាតិក៏អាចបាន។[19] មិនតែប៉ុណ្ណោះបើរកមិនឃើញសាច់ញាតិរបស់មតកជន ឬមតកជនមិនមានសាច់ញាតិបងប្អូន នាំឱ្យទ្រព្យសម្បត្តិអាចនឹងទៅជារបស់រដ្ឋ។[20]

តារាង៤៖ លំដាប់នៃសន្តតិជន

| លំដាប់នៃសន្តតិជន | ពិពណ៌នា |
|---|---|
| លំដាប់ទី១[21] | កូនរបស់មតកជន, ទោះកូនបង្កើត ឬកូនសុំក្តី។ |
| លំដាប់ទី២[22] | បុព្វញាតិរបស់មតកជន (ឪពុកម្តាយ, ជីដូនជីតា..)។ |
| លំដាប់ទី៣[23] | បងប្អូនបង្កើតរបស់មតកជន។ |

[16] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា១១៨៥(២)។
[17] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា១១៨៥(២)។
[18] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា១១៥៦-១១៦១។
[19] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា១២៩៩។
[20] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា១៣០០។
[21] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា១១៥៦។
[22] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា១១៥៩។

| | |
|---|---|
| សន្តតិជនជានិច្ច[24] | សហព័ទ្ធរបស់មតកជន (ប្ដី/ប្រពន្ធ)។ |

បើងាកមក សន្តតិកម្មប្រភេទទី២ គឺធ្វើឡើងដោយឆន្ទៈរបស់អ្នកស្លាប់ដោយរៀបរាប់ពីការចាត់ចែង ឬរបៀបដែលទ្រព្យសម្បត្តិរបស់ពួកគេគួរតែត្រូវបានបែងចែករួមបញ្ចូលព័ត៌មានជាក់លាក់ដល់បុគ្គលណាម្នាក់ដែលជាសន្តតិជន ឬតតិយជនផ្សេងៗទៀតដើម្បីឱ្យទទួលបានមត៌កបន្ត។

**១.២.២ លក្ខខណ្ឌក្នុងការបង្កើតមតកសាសន៍**

ចំពោះសន្តតិកម្មតាមមតកសាសន៍មានភាពស្មុគស្មាញច្រើនទាំងវិធានច្បាប់ និងនៅពេលចាប់ផ្ដើមការអនុវត្តបែងចែកមត៌ក ច្រើនជាងសន្តតិកម្មតាមច្បាប់។ ជាក់ស្ដែង នៅក្រោមគតិយុត្តច្បាប់របស់ប្រទេសកម្ពុជាមានបែងចែកមតកសាសន៍នេះជា ២ទម្រង់ធំៗ គឺ មតកសាសន៍ធម្មតា និងមតកសាសន៍ពិសេស។

ខាងក្រោមនេះគឺជា តារាងនៃទម្រង់មតកសាសន៍ធម្មតា និងទម្រង់ពិសេស៖

តារាង៥៖ ទម្រង់នៃមតកសាសន៍

| មតកសាសន៍ទម្រង់ធម្មតា | មតកសាសន៍ទម្រង់ពិសេស |
|---|---|
| មតកសាសន៍ដោយលិខិតយថាភូត[25] | មតកសាសន៍នៃជននៅក្រោមអាណាព្យាបាលទូទៅ[26] |
| មតកសាសន៍ដោយលិខិតឯកជន[27] | មតកសាសន៍របស់ជនដែលកំពុងជួបប្រទះគ្រោះថ្នាក់បន្ទាន់ដល់អាយុជីវិត[28] |
| មតកសាសន៍ដោយលិខិតសម្ងាត់[29] | មតកសាសន៍នៃជនដែលត្រូវជាប់ឃុំឃាំង[30] |
| | មតកសាសន៍នៃបុគ្គលដែលមិនអាចនិយាយបាន។[31] |

[23] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា១១៦០។
[24] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា១១៦១។
[25] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា១១៧៣។
[26] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា១១៧៦។
[27] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា១១៧៤។
[28] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា១១៧៧។
[29] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា១១៧៥។
[30] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា១១៧៨។
[31] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា១១៧៩។

មតកសាសន៍តាមទម្រង់ធម្មតាមានបីប្រភេទផ្សេងពីគ្នាទៀតគឺ មតកសាសន៍ដោយលិខិតយថាភូត មតកសាសន៍ដោយលិខិតឯកជន និងមតកសាសន៍ដោយលិខិតសម្ងាត់។[32] មតកសាសន៍ដោយលិខិតយថាភូតត្រូវធ្វើឡើង រវាងម្ចាស់បណ្តាំដែលជាមតកជន នៅចំពោះមុខសារការី ដោយសារការីមានតួនាទីថែរក្សាលិខិតមតកសាសន៍នោះ ដោយតាមស្មារតីរបស់មតកជន។ ទម្រង់នៃមតកសាសន៍នេះ ត្រូវគោរពតាមលក្ខខណ្ឌដែលបានកំណត់នៅក្នុងក្រមរដ្ឋប្បវេណីទើបធ្វើឱ្យទម្រង់នេះមានសុពលភាពគតិយុត្ត។ ដែលទម្រង់នោះត្រូវបានកំណត់៖

ក. ត្រូវមានវត្តមានរបស់សាក្សីយ៉ាងតិច២ (ពីរ) នាក់។

ខ. ម្ចាស់បណ្តាំត្រូវប្រាប់ផ្ទាល់មាត់ នូវខ្លឹមសារនៃមតកសាសន៍ ចំពោះសារការី។

គ. សារការីត្រូវសរសេរនូវអត្ថន័យនៃមតកសាសន៍របស់ម្ចាស់បណ្តាំនោះ ជាលាយលក្ខណ៍អក្សរ ហើយត្រូវសូត្រឱ្យម្ចាស់បណ្តាំ និងសាក្សីនោះស្តាប់។

ឃ. បន្ទាប់ពីម្ចាស់បណ្តាំ និងសាក្សីបានទទួលស្គាល់ថាកំណត់ជាលាយលក្ខណ៍អក្សរនោះត្រឹមត្រូវហើយ ជននីមួយៗនោះត្រូវធ្វើឱ្យមានភាពច្បាស់លាស់នៅលើឯកសារអំពីឈ្មោះ អាយុ និងលំនៅឋាន ហើយត្រូវចុះហត្ថលេខារៀងៗខ្លួន។ប៉ុន្តែបើម្ចាស់បណ្តាំ មិនអាចសរសេរអក្សរ ឬមិនអាចចុះហត្ថលេខាបានទេ សារការីអាចជំនួសការសរសេរ និងហត្ថលេខាដូចកំណត់ខាងលើនេះ ដោយសរសេរឈ្មោះ អាយុ និងលំនៅឋានរបស់ជននោះ ហើយត្រូវសរសេរបន្ថែមនូវហេតុនោះផង។[33]

ចំពោះមតកសាសន៍ដោយលិខិតឯកជនវិញ គឺជាលិខិតមួយដែលស្ថិតក្នុងចំណោមទម្រង់មតកសាសន៍ធម្មតា ក៏ប៉ុន្តែលក្ខខណ្ឌនៃលិខិតនេះ ខុសពីលិខិតពីរទៀត ត្រង់ ម្ចាស់បណ្តាំគឺជាអ្នកធ្វើលិខិតនេះដោយផ្ទាល់ខ្លួន ហើយម្ចាស់បណ្តាំត្រូវសរសេរពាក្យពេចន៍ទាំងឡាយដែលជាឆន្ទៈរបស់ខ្លួនទាំងអស់ចូលទៅក្នុងក្រដាស ព្រមទាំងចុះថ្ងៃខែឆ្នាំ និងហត្ថលេខាខាងលើលិខិតនោះដោយខ្លួនឯង។ ក្នុងករណីដែលមតកសាសន៍ដោយលិខិតឯកជននេះត្រូវបានធ្វើឡើង ដូចជាការសរសេរដោយអ្នកផ្សេងឬដោយប្រើឧបករណ៍ជំនួយផ្សេងៗដែលមានដូចជា កុំព្យូទ័រជាអាទិ៍ លិខិតនេះនឹងត្រូវចាត់ទុកជាមោឃៈ។ នៅក្នុងករណីមានការបន្ថែមពាក្យពេចន៍ ការលុប ឬការកែប្រែផ្សេងៗទៀតនៅក្នុងមតកសាសន៍លិខិតឯកជន ពុំមានអានុភាពឡើយ បើម្ចាស់បណ្តាំមិនអាចបង្ហាញពីកន្លែងកែ ហើយសរសេរបន្ថែមនូវហេតុនៃការកែប្រែនោះ ជាពិសេសបើមិនបានចុះហត្ថលេខា។[34] ចំណែកមតកសាសន៍ដោយលិខិតសម្ងាត់ ត្រូវធ្វើឡើងដោយយោងតាមលក្ខខណ្ឌទម្រង់៖

ក. ម្ចាស់បណ្តាំត្រូវចុះហត្ថលេខាលើលិខិតនោះ។

ខ. ម្ចាស់បណ្តាំត្រូវដាក់លិខិតនោះក្នុងស្រោមបិទជិត ហើយត្រូវចុះហត្ថលេខា ឬសរសេរសញ្ញាសំគាល់ ឬមធ្យោបាយផ្សេងទៀតដែលអាចវិនិច្ឆ័យបានអំពីការបានបើក ឬមិនបានបើកស្រោមលិខិតនោះនៅមាត់ស្រោមលិខិតនោះ។

[32] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា១១៧-១១៧៥។

[33] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា១១៧៣។

[34] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា១១៧៤។

គ. ម្ចាស់បណ្តាំត្រូវដាក់លិខិតដែលបានបិទជិតនោះ នៅចំពោះមុខសារការីម្នាក់ និងសាក្សី ២(ពីរ) នាក់ និងធ្វើសេចក្តីថ្លែងការណ៍ថា លិខិតនេះជាលិខិតមតកសាសន៍របស់ខ្លួន ហើយបើមានជនក្រៅពីសមីខ្លួនបានសរសេរ ត្រូវធ្វើសេចក្តីថ្លែងការណ៍អំពីឈ្មោះ និងលំនៅឋានរបស់ជនដែលបានសរសេរនោះ។

ឃ. សារការីត្រូវចុះថ្ងៃខែឆ្នាំដែលសាមីខ្លួនបានដាក់លិខិតនោះ និងសរសេរសេចក្តីថ្លែងការណ៍របស់ម្ចាស់បណ្តាំ នៅលើលិខិតដែលបិទជិតនោះ ហើយត្រូវចុះហត្ថលេខាលើលិខិតនោះជាមួយគ្នានឹងសាក្សី និងម្ចាស់បណ្តាំ។[35]

ចំណែកឯមតកសាសន៍ទម្រង់ពិសេសមានបួន ប្រភេទផ្សេងៗទៀតគឺ មតកសាសន៍នៃជននៅក្រោមអាណាព្យាបាលទូទៅ មតកសាសន៍របស់ជនដែលកំពុងជួបប្រទះគ្រោះថ្នាក់បន្ទាន់ដល់អាយុជីវិត មតកសាសន៍នៃជនដែលត្រូវជាប់ឃុំឃាំង និងមតកសាសន៍នៃបុគ្គលដែលមិនអាចនិយាយបាន។ ដែលប្រភេទមតកសាសន៍ក្នុងទម្រង់ពិសេសនេះ គឺធ្វើឡើងក្នុងលក្ខខណ្ឌមួយដែលមតកជនមិនអាចធ្វើឡើងដោយឯកឯងបាន ពោលគឺទាមទារលក្ខខណ្ឌច្រើនលើសពីមតកសាសន៍ទម្រង់ធម្មតា។ ខាងក្រោមជាតារាងបង្ហាញពីប្រភេទផ្សេងៗនៃទម្រង់មតកសាសន៍ពិសេស និងលក្ខខណ្ឌ។

តារាង៦៖ ប្រភេទ និងលក្ខខណ្ឌផ្សេងៗ នៃទម្រង់មតកសាសន៍ពិសេស

| ប្រភេទនៃមតកសាសន៍ | លក្ខខណ្ឌទម្រង់ |
|---|---|
| មតកសាសន៍នៃជនក្រោមអាណាព្យាបាលទូទៅ[36] | • ដើម្បីធ្វើមតកសាសន៍នៅពេលដែលជននៅក្រោមអាណាព្យាបាលទូទៅ បានសះស្បើយមួយរយៈឡើងវិញនូវសមត្ថភាពក្នុងការយល់ដឹង និងវិនិច្ឆ័យអំពីលទ្ធផលតាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួន ត្រូវមានវត្តមានរបស់វេជ្ជបណ្ឌិត យ៉ាងតិច ២(ពីរ)នាក់។ <br> • វេជ្ជបណ្ឌិតដែលមានវត្តមាននៅពេលធ្វើមតកសាសន៍ ត្រូវសរសេរបញ្ជាក់បន្ថែមលើលិខិតមតកសាសន៍នោះថា នៅពេលដែលម្ចាស់បណ្តាំបានធ្វើមតកសាសន៍នោះម្ចាស់បណ្តាំពុំបានស្ថិតក្នុងស្ថានភាពខ្វះសមត្ថភាពក្នុងការយល់ដឹង និងវិនិច្ឆ័យអំពីលទ្ធផលតាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួនដោយសារមានវិបត្តិស្មារតីទេ ហើយត្រូវចុះហត្ថលេខាដោយបញ្ជាក់ថាខ្លួនជាវេជ្ជបណ្ឌិតផងដែរ។ |
| មតកសាសន៍របស់ជនដែលកំពុង | • ប្រសិនបើជនដែលកំពុងជួបប្រទះគ្រោះថ្នាក់ដល់អាយុជីវិត |

[35] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា១១៧៥។

[36] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា១១៧៦។

| | |
|---|---|
| ជួបប្រទះគ្រោះថ្នាក់បន្ទាន់ដល់អាយុជីវិត[37] | ដោយសារជំងឺ ឬហេតុផ្សេងទៀត មានបំណងចង់ធ្វើមតកសាសន៍ មតកសាសន៍នេះអាចធ្វើបានដោយតម្រូវវត្តមានរបស់សាក្សីយ៉ាងតិច ៣នាក់ ហើយដោយប្រកាសខ្លឹមសារនៃមតកសាសន៍នោះ ដោយផ្ទាល់មាត់ ចំពោះជនម្នាក់ក្នុងចំណោមសាក្សីនោះ។ នៅក្នុងករណីនេះជនដែលបានទទួលការប្រកាសដោយផ្ទាល់មាត់នោះត្រូវសរសេរជាលាយលក្ខណ៍អក្សរ ហើយអានឱ្យសាក្សីស្ដាប់ ឬឱ្យមើល ហើយនៅក្រោយពេលដែលសាក្សីនីមួយៗបានទទួលស្គាល់ថាការសរសេរនោះត្រឹមត្រូវហើយសាក្សីនីមួយៗនោះត្រូវចុះហត្ថលេខាលើលិខិតនោះ។<br>• មតកសាសន៍ដែលបានធ្វើឡើងតាមចំណុចខាងលើ នឹងមិនមានអានុភាពឡើយប្រសិនបើសាក្សីណាម្នាក់ ឬបុគ្គលណាម្នាក់ដែលពាក់ព័ន្ធនឹងផលប្រយោជន៍ ពុំបានដាក់ពាក្យសុំទៅតុលាការនៅក្នុងអំឡុងពេល១ខែដោយគិតចាប់ពីថ្ងៃដែលបានធ្វើមតកសាសន៍ ហើយពុំបានទទួលបញ្ជាក់ទេនោះ។<br>• តុលាការមិនអាចធ្វើការបញ្ជាក់មតកសាសន៍បានឡើយប្រសិនបើពុំមានជំនឿទុកចិត្តថាមតកសាសន៍នោះចេញពីឆន្ទៈពិតប្រាកដរបស់ម្ចាស់បណ្ដាំ។ |
| មតកសាសន៍នៃបុគ្គលដែលត្រូវជាប់ឃុំឃាំងជាអាទិ៍[38] | • បុគ្គលដែលជាប់ឃុំឃាំងនៅទីកន្លែងដាច់ដោយឡែកដោយសាលក្រម ឬសាលដីកា ឬដោយការចាត់ចែងផ្នែករដ្ឋបាល ធ្វើឱ្យលិខិតមតកសាសន៍បានដោយត្រូវឱ្យមានវត្តមានរបស់នគរបាល ឬមន្ត្រីនៃមន្ទីរឃុំឃាំងម្នាក់ និងសាក្សី យ៉ាងតិច ២នាក់។<br>• បុគ្គលដែលនៅក្នុងនាវា ឬយន្តហោះ អាចធ្វើលិខិតមតកសាសន៍បាន ដោយត្រូវឱ្យមានមេបញ្ជាការនាវា ឬយន្ត |

[37] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា១១៧៧។

[38] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា១១៧៨។

| | |
|---|---|
| | ហោះ ឬបុគ្គលិកនាវា ឬយន្តហោះម្នាក់ និងសាក្សីយ៉ាងតិច ២នាក់។<br>• មតកសាសន៍ដែលបានកំណត់ក្នុងចំណុច ទាំងពីរខាងលើនេះ ម្ចាស់បណ្ដាំអាចធ្វើមតកសាសន៍បានដោយផ្ទាល់មាត់ចំពោះបុគ្គលដែលបានរៀបរាប់ទាំងពីរចំណុចខាងលើ។<br>• ម្ចាស់បណ្ដាំត្រូវប្រាប់ផ្ទាល់មាត់នូវខ្លឹមសារនៃមតកសាសន៍ចំពោះនគរបាល មន្ត្រីនៃមន្ទីរឃុំឃាំង មេបញ្ជាការ បរិបាលនាវា ឬយន្តហោះ ឬបុគ្គលិកនាវា ឬយន្តហោះ។<br>• មតកសាសន៍ដែលធ្វើឡើងតាម បួនចំណុចខាងលើនេះ ពុំមានអានុភាពឡើយ បើម្ចាស់បណ្ដាំបន្តនៅរស់ ក្នុងអំឡុងពេល ៦ខែ គិតចាប់ពីពេលដែលម្ចាស់បណ្ដាំនោះ បែរជាអាចធ្វើមតកសាសន៍ តាមទម្រង់ណាមួយនៃមតកសាសន៍ធម្មតាទាំង៣ ក្រោយពេលដែលខ្លួនត្រូវបានដោះលែងពីមន្ទីរឃុំឃាំង ឬចុះពីនាវា ឬយន្តហោះ។ |
| មតកសាសន៍នៃបុគ្គលដែលមិនអាចនិយាយបានជាអាទិ៍[39] | • ករណីបុគ្គលដែលបុគ្គលមិនអាចនិយាយបានធ្វើមតកសាសន៍តាមទម្រង់ដែលបានកំណត់នៅក្នុងមាត្រា១១៧៣ (មតកសាសន៍ដោយលិខិតយថាភូត) មាត្រា១១៧៥ (មតកសាសន៍ដោយលិខិតសម្ងាត់) និងមាត្រា១១៧៧ (មតកសាសន៍របស់ជនដែលកំពុងជួបប្រទះគ្រោះថ្នាក់បន្ទាន់ដល់អាយុជីវិត) ម្ចាស់បណ្ដាំអាចជំនួសការប្រាប់បានដោយធ្វើសេចក្ដីថ្លែងការណ៍អំពីខ្លឹមសារនៃមតកសាសន៍ ឬសេចក្ដីថ្លែងការណ៍ថាលិខិតនោះជាលិខិតមតកសាសន៍តាមការបកប្រែរបស់អ្នកបកប្រែ ឬសរសេរដោយដៃខ្លួនផ្ទាល់ ចំពោះមុខសារការី ឬសាក្សី។ |
| មតកសាសន៍ចំពោះជនជាតិខ្មែរដែលរស់នៅបរទេស[40] | • ករណីមតកសាសន៍ចំពោះជនជាតិខ្មែរដែលរស់នៅបរទេស មានបំណងចង់បង្កើតនូវមតកសាសន៍ដោយ |

[39] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា១១៧៩។
[40] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា១១៨១។

| | |
|---|---|
| | លិខិតយថាភូត ឬលិខិតសម្ងាត់ បុគ្គលនោះអាចធ្វើទៅបានដោយគ្រាន់តែទៅកន្លែងដែលមានកុងស៊ុលនៃព្រះរាជាណាចក្រកម្ពុជាប្រចាំនៅ កុងស៊ុលនោះនឹងដើរតួនាទីជំនួសឱ្យសារការី។ |

តារាងខាងលើបង្ហាញពី ទម្រង់ផ្សេងៗនៃមតកសាសន៍ទាំង ទម្រង់ធម្មតា និងទម្រង់ពិសេស។ ទោះបីជាមានការចែងយ៉ាងច្បាស់អំពីលក្ខខណ្ឌនិងរបៀបក្នុងការតាក់តែង ភាពស្មុគស្មាញច្រើនហាក់ដូចជាកើតឡើងទាំងប្រព័ន្ធច្បាប់ នឹងការអនុវត្ត។ ជាក់ស្តែងការយល់ដឹងពីការបែងចែកមត៌កទៅឱ្យអ្នកជំនាន់ក្រោយគឺជា ផ្នត់គំនិតមួយដែលចាក់ឫសគុលយ៉ាងជ្រៅក្នុងខួរក្បាលប្រជាពលរដ្ឋដែលជាមូលហេតុនៃការកើតឡើងក្នុងការអនុវត្តប្រចាំថ្ងៃ។ "ការខិតខំប្រឹងប្រែងរកស៊ីចិញ្ចឹមជីវិតរបស់គ្រួសារនីមួយៗ ក្រៅពីចង់រស់នៅក្នុងស្ថានភាពមួយសមរម្យនិងល្អប្រសើរ អ្វីដែលសំខាន់ជាងនេះគឺ ឪពុកម្តាយមានគំនិតមួយគឺការបន្សល់ទុកកេរមត៌កជូនទៅកូនចៅជំនាន់ក្រោយបន្ទាប់ពីពួកគាត់ទទួលមរណភាព។"[41]

[41] ហាម កុកយូ (សមាជិកមេធាវី នៃការិយាល័យមេធាវី បន្ទាយក្តី), បទសម្ភាសដោយ បាទ ជីយុន, ៧ កក្កដា ២០២៤។

# ជំពូកទី២

# ការអនុវត្តសន្តិកម្មនៅកម្ពុជា

# ជំពូកទី២ ការអនុវត្តសន្តតិកម្មនៅកម្ពុជា

## ២.១ ដំណើរការក្នុងការប្រតិបត្តិមតកសាសន៍

ដូចបានពិភាក្សានៅចំណុច១.២ខាងលើ សន្តតិកម្មចាប់ផ្តើមនៅពេលដែលមរណភាពនៃមតកជន។ នៅពេលដែលសន្តតិជន បានដឹងថាមានមតកសាសន៍ នោះការបែងចែកមត៌កនឹងត្រូវធ្វើឡើងទៅតាមឆន្ទៈដែលត្រូវបានសរសេរដោយមតកជននៅក្នុងមតកសាសន៍នោះ។ មតកសាសន៍ដែលមានចែងនៅក្នុងក្រមរដ្ឋប្បវេណីក៏មានច្រើនប្រភេទផងដែរ ដែលក្នុងនោះមានការបែងចែកជាពីរប្រភេទធំ គឺទម្រង់ធម្មតា និងទម្រង់ពិសេស។ ដូច្នេះហើយ ក្នុងករណីដែលមានវត្តមានមតកសាសន៍ មិនថាប្រភេទ និងទម្រង់ណានោះទេ ការបែងចែកមត៌កនឹងធ្វើតាមការសរសេរបែងចែកដូចខ្លឹមសារដែលពិភាក្សា នៅចំណុចបន្ទាប់នៃសារណានេះត្រូវចំណុច (២.១.១)។

### ២.១.១ ការបែងចែកតាមមតកសាសន៍

ទោះបីជាលក្ខខណ្ឌផ្សេងៗ ក្នុងការបង្កើតមតកសាសន៍ត្រូវបានកម្រិតដោយច្បាប់ ម្ចាស់បណ្តាំនៅតែមានសិទ្ធិពេញលេញក្នុងការកំណត់ពីចំណែក និងរបៀបក្នុងការបែងចែកដោយសេរីតាមឆន្ទៈរបស់ខ្លួន។ ចំពោះចំណែកមត៌ករបស់សន្តតិជនដែលមតកជនបានកំណត់តាមរយៈមតកសាសន៍នេះហៅថា ចំណែកមត៌កតាមការកំណត់ ហើយអាចធ្វើការកំណត់នូវសមាមាត្រប្រភាគ ឬកំណត់នូវទ្រព្យជាក់ស្តែងណាមួយទៅឱ្យសហសន្តតិជនណាមួយបាន។[42] ជាក់ស្តែង ការបែងចែកតាមមតកសាសន៍នេះក៏អាចមានការប្រែប្រួលផងដែរ អាស្រ័យលើផលប្រយោជន៍ពិសេសដែលសន្តតិជនទទួលបានមុនពេលសន្តតិកម្មចាប់ផ្តើម ដូចជាប្រទានកម្មនៅក្នុងឱកាសអាពាហ៍ពិពាហ៍ ឬហេតុការណ៍ផ្សេងទៀត ឬដើម្បីមូលធននៃជីវភាពរស់នៅ ឬបានទទួលអច្ច័យទានពីមតកជននោះនៅពេលដែលសន្តតិកម្មចាប់ផ្តើម ចំណែកមត៌កដែលជននោះត្រូវទទួលបានត្រូវយកមកកាត់កងនឹងផលប្រយោជន៍ពិសេសនោះសិន ទើបរកឃើញតម្លៃពិតប្រាកដនៃចំណែកមត៌កដែលអាចទទួលបាន។[43] ទោះបីជាការបង្កើតមតកសាសន៍ជាសកម្មភាពឯកតោភាគី ដែលម្ចាស់បណ្តាំមានសិទ្ធិពេញលេញក្នុងការសរសេរនូវអ្វីដែលជាឆន្ទៈរបស់ខ្លួន ប៉ុន្តែក៏មិនអាចផ្ទុយនឹងបញ្ញត្តិនៃភាគបម្រុងបានដែរ[44] ដែលនឹងពិភាក្សាលំអិតនៅចំណុច (២.២.២.១)។ ទោះបីជាមានការកំណត់ចំណែកមត៌កដែលធ្វើឡើងដោយមតកជនសរសេរក្នុងមតកសាសន៍ក៏ការបែងចែកមត៌កត្រូវពិចារណាទៅលើការកំណត់វិធីបែងចែក និងចំណុចផ្សេងៗមួយចំនួនទៀតផងដែរ។ មតកជនអាចធ្វើការកំណត់នូវវិធីបែងចែកមត៌កបាន ដូចជាតាម រយៈការកំណត់ថា សហសន្តតិជនណាទទួលបានទ្រព្យជាក់លាក់ណាមួយស្របទៅតាមឆន្ទៈរបស់ខ្លួន។

[42] សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី របស់ក្រសួងយុត្តិធម៌, ភាគ៦៖ គន្ថីទី៨-៩, ២០១០, ២៥។

[43] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា១១៦៣។

[44] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា១១៨២(១)។

នៅពេលដែលមានមតកសាសន៍ បង្កើតឡើងត្រឹមត្រូវតាមលក្ខខណ្ឌទម្រង់ដែលច្បាប់កំណត់ នោះការបែងចែកទៅឱ្យសហសន្តតិជននីមួយៗ នឹងធ្វើតាមការចែងក្នុងមតកសាសន៍នោះផងដែរ។[45] ទោះបីជាមានការបង្ហាញអំពីលក្ខខណ្ឌទម្រង់ដើម្បីឱ្យមតកសាសន៍មានសុពលភាពអាចអនុវត្តបាន ក៏បញ្ហាអសុពលភាពបានកើតឡើងជាច្រើននៅក្នុងការអនុវត្តជាក់ស្តែងដែលធ្វើឱ្យការបែងចែកមិនអាចត្រូវបានធ្វើឡើងតាមការចែងសរសេរនៅក្នុងមតកសាសន៍ដោយប្តូរទៅជាការបែងចែកតាមច្បាប់ ឬការបែងចែកដោយការស្រុះស្រួលគ្នារវាងសហសន្តតិជនទាំងឡាយដែលមានសិទ្ធិទទួលមត៌ក ដែលនឹងពិភាក្សានៅចំណុច (២.១.២) ខាងក្រោម។

### ២.១.២ ការស្រុះស្រួលគ្នាក្នុងការបែងចែកមត៌ក

ទោះបីជាមានវត្តមានមតកសាសន៍ ដោយការបែងចែកមត៌កទាំងឡាយត្រូវធ្វើស្របតាមការសរសេរដោយមតកជននៅក្នុងមតកសាសន៍ ក៏ប្រតិបត្តិការបែងចែកមត៌កក្នុងតថភាពសង្គមបច្ចុប្បន្ននៅតែជាករណីមួយមានភាពលំបាកស្មុគស្មាញ។ ដូចបានបង្ហាញនៅក្នុងចំណុច ២.១.១ ខាងលើ អំពីលក្ខខណ្ឌទម្រង់ដែលធ្វើឱ្យមតកសាសន៍មានសុពលភាពជាលក្ខខណ្ឌសំខាន់ដើម្បីអាចឱ្យមតកសាសន៍នោះអនុវត្តបានក៏ពិតមែន តែការបង្កើតមតកសាសន៍ដោយខុសទម្រង់នៅតែជាប្រធានបទដ៏ស្មុគស្មាញ និងបង្កបញ្ហាជាហេតុនាំឱ្យមានការបែងចែកត្រូវធ្វើឡើងតាមរយៈការកំណត់ដោយច្បាប់។ នៅពេលដែលមតកសាសន៍ធ្វើឡើងដោយខុសទម្រង់ដែលចែងដោយច្បាប់ មតកសាសន៍នឹងមិនអាចអនុវត្តបាននោះទេ លើកលែងមានការអនុញ្ញាត ឬដោយការស្រុះស្រួលគ្នារវាងសហសន្តតិជនទាំងឡាយដោយមានព្រមព្រៀងក្នុងការបែងចែកទើបអាចប្រព្រឹត្តទៅបាន។ ផ្ទុយទៅវិញប្រសិនបើសហសន្តតិជនមិនស្រុះស្រួលឬឈ្លោះប្រកែកគ្នាអំពីចំណែកមត៌ក ឬវិធីក្នុងបែងចែកមត៌កនោះការបែងចែកមត៌កនឹងធ្វើតាមច្បាប់ដោយស្ថាប័នតុលាការ។

ទោះបីមតកសាសន៍ត្រូវបានធ្វើឡើងត្រឹមត្រូវតាមលក្ខខណ្ឌទម្រង់ក៏ដោយ ក៏ការសម្រុះសម្រួលគ្នារវាងសហសន្តតិជនទាំងឡាយនៅតែអាចត្រូវបានធ្វើឡើងក្នុងករណីមួយចំនួនផ្សេងទៀត។ ពេលខ្លះទ្រព្យសម្បត្តិនានាដែលមតកជនសរសេររៀបរាប់នៅក្នុងមតកសាសន៍ មិនបានពណ៌នាអំពីទ្រព្យសម្បត្តិទាំងអស់ដែលមានជាកម្មសិទ្ធិរបស់មតកជនមាននោះទេ។ ជាឧទាហរណ៍ មតកជនមានទ្រព្យសម្បត្តិជាដីធ្លីចំនួន៥កន្លែង តែមតកជនបានសរសេររៀបរាប់ទៅក្នុងមតកសាសន៍ ចំនួនតែ៣កន្លែង។ ជាហេតុបានបង្កលក្ខខណ្ឌពិបាកធ្វើឱ្យ ទ្រព្យដែលមតកជនមាន តែអវត្តមានក្នុងមតកសាសន៍មិនអាចអនុវត្តបាន ឬមិនមានការចង្អុលបង្ហាញអំពីការបែងចែកនៅក្នុងមតកសាសន៍។ តើការអនុវត្តនឹងទៅជាបែបណាប្រសិនបើមានករណីនេះកើតឡើង? ជាក់ស្តែងហេតុការណ៍នេះកើតមានជាញឹកញាប់អាស្រ័យទៅតាមស្ថានភាពនានា។ ពេលខ្លះកើតឡើងដោយសារមតកជនបានធ្វើមតកសាសន៍

[45] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា១១៧១។

ក្នុងអំឡុងពេលយូរពេកមុនទទួលមរណភាព ហើយបានទិញទ្រព្យសម្បត្តិបន្ថែមដោយមិនបានកែប្រែខ្លឹមសារនៃមតកសាសន៍ ឬធ្វើបច្ចុប្បន្នភាពនៃមតកសាសន៍ដែលជាហេតុធ្វើឱ្យមានហេតុការណ៍នេះកើតឡើងនៅពេល មតកជនទទួលមរណភាព។ លើសពីនេះទ្រព្យសម្បត្តិដែលមិនបានសរសេរចែងនៅក្នុងមតកសាសន៍ មិនអាចបែងចែកតាមមតកសាសន៍ទេគឺតម្រូវឱ្យធ្វើការបែងចែកស្របតាមការចែងដោយច្បាប់ទៅតាមលំដាប់នៃសន្តតិជន។[46] ទោះបីជាមានលក្ខខណ្ឌ ដូចបានបង្ហាញខាងលើនេះក៏ដោយ ទ្រព្យសម្បត្តិដែលមិនបានចែងនៅក្នុងមតកសាសន៍នៅតែអាចបែងចែកក្រៅប្រព័ន្ធតុលាការក្នុងលក្ខខណ្ឌផ្សេងទៀតផងដែរ។ ប្រសិនបើសហសន្តតិជនទាំងឡាយស្រុះស្រួលគ្នាដោយមិនមានការឈ្លោះប្រកែកក្នុងការបែងចែកនូវទ្រព្យសម្បត្តិដែលអវត្តមានក្នុងមតកសាសន៍នោះនឹងអាចប្រព្រឹត្តទៅបាន ឬពេលខ្លះទៀតមានការសម្របសម្រួលពីស្ថាប័នណាមួយដូចជាស្ថាប័នតុលាការ។ ជាឧទាហរណ៍ កាលពីដើម ខែសីហា ឆ្នាំ២០២៤ ក្រោមកិច្ចដឹកនាំរបស់ប្រធានសាលាដំបូងខេត្តតាកែវ បានផ្តល់ជូននូវដំណោះស្រាយឈ្នះៗក្នុងការសម្របសម្រួលផ្សះផ្សា ដល់ភាគីវិវាទក្នុងរឿងប្តឹងសុំបែងចែកមត៌កដែលជាដីចំនួន៧ប័ណ្ណ។[47] ករណីជាក់ស្តែងមួយទៀត ក្រោមការសម្របសម្រួលពីប្រធានសាលាឧទ្ធរណ៍ភ្នំពេញ ដល់ភាគីវិវាទក្នុងរឿងជម្លោះបែងចែកមត៌កឱ្យស្រុះស្រួលក្នុងការបែងចែកមត៌ក ដោយសាលាឧទ្ធរណ៍បានចេញលិខិតសះជាហើយកាត់ក្តីតម្រូវឱ្យខាងភាគីដើមបណ្តឹង និងចុងបណ្តឹងទទួលបានទ្រព្យសមគួរ។[48] ការស្រុះស្រួលក៏អាចធ្វើឡើងក្នុងរង្វង់តែភាគីវិវាទបានដែរ ដោយគ្រាន់តែមានការព្រមព្រៀងដោយស្មោះអស់ពីចិត្ត នោះការដោះស្រាយនឹងអាចកើតឡើងបាន។ ការស្រុះស្រួលតែភាគីអាចមានផលវិបាកផងដែរដោយសារតែការបែងចែកនេះធ្វើទៅតាមការស្រុះស្រួលគ្នារវាងសហសន្តតិជន ដូចនេះវាអាចនឹងនាំឱ្យមានភាពឈ្លោះប្រកែកគ្នាឬមានវិវាទនៅថ្ងៃអនាគតពេលដែលសហសន្តតិជននីមួយៗមិនត្រូវរ៉ូវគ្នានៅថ្ងៃខាងមុខ។

## ២.២ ភាពស្មុគស្មាញក្នុងការបែងចែកមត៌ក

ទោះបីជាការបង្កើតមតកសាសន៍ធ្វើឱ្យការបែងចែកមត៌កកាន់តែមានភាពងាយស្រួល នឹងជៀសវាងពីការឈ្លោះប្រកែករវាងសហសន្តតិជនទាំងឡាយដែលមានសិទ្ធិទទួលមត៌កក៏ដោយ ភាពស្មុគស្មាញក្នុងការបែងចែកមត៌កនៅតែមានក្នុងសង្គមបច្ចុប្បន្ន។ ភាពងាយស្រួលនៃការបែងចែកមត៌កតាមមតកសាសន៍មិនមែនសុទ្ធសឹងតែរលូនទៅមុខរហូតនោះទេ ការបង្កើតមតកសាសន៍ដោយខុសទម្រង់នៅតែជាបញ្ហាមួយឈានមុខគេ ដូចបានពិភាក្សានៅចំណុចខាងលើ ដែលជាហេតុធ្វើឱ្យការបែងចែកមត៌កនោះមិនអនុវត្តតាមមតកសាសន៍ (២.២.១) និង

[46] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា១១៥៦-១១៦០។

[47] FBR Plus News, "លោកជំទាវ ពេជ ម៉ាឌីន ប្រធានសាលាដំបូងខេត្តតាកែវ សម្របសម្រួលផ្សះផ្សាបញ្ចប់វិវាទករណីប្តឹងសុំបែងចែកមត៌កប្រកបដោយជោគជ័យ," ៧ សីហា ២០២៤។

[48] ទ្រី រ៉ាវី, "ទីបំផុតរឿងក្តីបណ្តាំមរតករបស់គ្រួសារ ស៊ូ ស៊ីរីកា និងជុំ រស្មី ឈានដល់ទីបញ្ចប់ដោយសន្តិវិធី," https://infotainment.ams.com.kh/celebrity/news/finally-the-case-of-sou-sirika-and-chum-raksmey-inheritance-came-to-a-peaceful-end/ (ទស្សនាចុងក្រោយ ១៥ សីហា ២០២៤)។

ពេលខ្លះមតកសាសន៍បានធ្វើឡើងដោយត្រឹមត្រូវស្របតាមលក្ខខណ្ឌទម្រង់ដែលច្បាប់តម្រូវតែមតកសាសន៍នោះប៉ះពាល់ដល់ផលប្រយោជន៍របស់សន្តតិជន (២.២.២)។

### ២.២.១ ការមិនអនុវត្តតាមមតកសាសន៍

#### ២.២.១.១ មតកសាសន៍ដែលខុសទម្រង់

នៅពេលដែលមានវត្តមាន មតកសាសន៍សន្តតិជនទាំងអស់ត្រូវយកមតកសាសន៍នោះមកអនុវត្តតែការអនុវត្តជាក់ស្តែងមតកសាសន៍ដែលបង្កើតឡើងដោយមតកជន មិនអាចសុទ្ធតែយកមកអនុវត្តបាននោះទេនៅក្នុងស្ថានភាពមួយចំនួន។ ករណីមតកសាសន៍ដែលមតកជនធ្វើឡើងខុសទម្រង់ណាមួយដែលជាលក្ខខណ្ឌចាំបាច់ចែងនៅក្នុងច្បាប់ មតកសាសន៍មិនអាចមានសុពលភាពអនុវត្តបាននោះទេ ពោលគឺបង្កើតនូវផលវិបាក និងភាពស្មុគស្មាញក្នុងការបែងចែកមត៌កផងដែរជាហេតុធ្វើឱ្យការបែងចែកមត៌កនោះត្រូវបែងចែកតាមច្បាប់កំណត់។ ទម្រង់នៃមតកសាសន៍នេះគឺជាលក្ខខណ្ឌមួយដែលត្រូវអនុវត្តតាមជាចាំបាច់ក្នុងការធានាឱ្យបាននូវភាពស្របច្បាប់ នៃមតកសាសន៍ដែលមានសុពលភាពអាចអនុវត្តបាន។

ទោះបីជា មតកសាសន៍ត្រូវបានធ្វើដោយឆន្ទៈពិតប្រាកដរបស់ មតកជនក៏ដោយ ក្នុងស្ថានភាពខ្លះមិនអាចអនុវត្តបានទេ។ ការធ្វើមតកសាសន៍មិនថាក្នុងប្រភេទមតកសាសន៍ជាប្រភេទលិខិតយថាភូត លិខិតឯកជន ឬលិខិតសម្ងាត់[49] ប្រសិនជាធ្វើខុសលក្ខខណ្ឌទម្រង់ណាមួយ ឬខ្វះនូវចំណុចណាមួយដែលច្បាប់តម្រូវជាចាំបាច់ក្នុងការធ្វើឱ្យអត្ថិភាពស្របច្បាប់នៃមតកសាសន៍ សន្តតិជនមិនអាចយកមតកសាសន៍នោះមកអនុវត្តបានដែរ។ ជាឧទាហរណ៍ មតកសាសន៍ដែលធ្វើឡើងដោយលិខិតឯកជន ច្បាប់តម្រូវឱ្យមតកជនសរសេរដោយផ្ទាល់ដៃនូវពាក្យផ្តែផ្តាំ ឬការបែងចែកមត៌កណាមួយទៅឱ្យសន្តតិជនណាម្នាក់តាមឆន្ទៈរបស់ខ្លួននៅក្នុងក្រដាស[50] ប៉ុន្តែមតកជនបានប្រើប្រាស់កុំព្យូទ័រដើម្បីសរសេរដោយគិតថាងាយស្រួលក្នុងការមើលនិងដើម្បីកុំឱ្យមានអ្នកលួចកែប្រែ ដូច្នេះក្នុងករណីនេះនៅពេលដែលមតកជនបានទទួលមរណភាពមតកសាសន៍នោះមិនអាចប្រើប្រាស់បានទេ ដោយសារតែខុសទម្រង់ដែលច្បាប់បានកំណត់។[51] ទម្រង់ទាំងនេះគឺជាលក្ខខណ្ឌចាំបាច់ដែលអាចឱ្យតុលាការទទួលស្គាល់នឹងបែងចែកដោយចេញដីកាសម្រេចចែកតាមមតកសាសន៍នោះ បើមិនដូច្នេះទេ តុលាការនឹងធ្វើការបដិសេធចំពោះមតកសាសន៍នឹងបន្តនីតិវិធីប្តូរការបែងចែកតាមច្បាប់វិញ។[52] ជាឧទាហរណ៍ជាក់ស្តែង សាលក្រមចេញ

---

[49] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា១១៧៣-១១៧៥។

[50] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា១១៥៦-១១៧៤។

[51] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា១១៤៥(២)។

[52] សំណុំរឿងរដ្ឋប្បវេណីមិនមែនបណ្តឹង រវាង ស៊ូ ស៊ីរីកា និងជុំ រស្មី, ត្រូវបានសាលាឧទ្ធរណ៍បដិសេធចោលមតកសាសន៍ដោយសារខុសទម្រង់, https://infotainment.ams.com.kh/celebrity/news/finally-the-case-of-sou-sirika-and-chum-raksmey-inheritance-came-to-a-peaceful-end/ (ទស្សនាចុងក្រោយ ១៥ សីហា ២០២៤)។

ដោយសាលាដំបូងរាជធានីភ្នំពេញនៅឆ្នាំ២០១៩មិនទទួលស្គាល់មតកសាសន៍តាមទម្រង់ដោយផ្ទាល់មាត់ ដោយមតកជននោះទេជាហេតុការបែងចែកមត៌កត្រូវធ្វើឡើងតាមច្បាប់។[53]

### ២.២.១.២ មតកសាសន៍ដែលបង្កើតដោយបុគ្គលខ្វះសមត្ថភាព

ការបង្កើតមតកសាសន៍ ដែលត្រឹមត្រូវតាមទម្រង់លក្ខខណ្ឌចែងដោយច្បាប់ មិនមែនមានន័យថាអាចយកមកអនុវត្តនៅក្នុងគ្រប់កាលៈទេសៈបានទេ។ ការអនុវត្តជាក់ស្តែង ទោះបីជាមានការពិនិត្យមើលអំពីអត្ថិភាពនៃមតកសាសន៍ដោយស្របច្បាប់ក៏ដោយ នៅតែមានចំណុចនៃការលើកឡើងប្រឆាំង ឬ មានភស្តុតាងបង្ហាញពីនត្ថិភាពនៃភាពស្របច្បាប់របស់មតកសាសន៍ដែលធ្វើឱ្យមិនអាចអនុវត្តបាននៃមតកសាសន៍នោះ។ ការបង្កើតមតកសាសន៍ មានតែនីតិជនប៉ុណ្ណោះដែលអាចមានសិទ្ធិធ្វើមតកសាសន៍បាន ឬអនីតិជនណាដែលមានសិទ្ធិគ្រប់គ្រាន់។[54] ផ្អែកតាមមាត្រា១១៦៨ កថាខណ្ឌទី១ ចែងថាជនដែលមានបំណងធ្វើមតកសាសន៍ មានអាយុចាប់ពី ១៨ឆ្នាំឡើងទៅ នីតិជន ដូច្នេះទោះបីជាជននោះស្ថិតនៅក្រោមអាណាព្យាបាលទូទៅក៏អាចធ្វើមតកសាសន៍បានដែរ។ ការធ្វើមតកសាសន៍តាមការលើកឡើងនេះ ត្រូវធ្វើឡើងដោយនីតិជន ឬអនីតិជនដែលបានទទួលមានអត្តាធិនភាព។[55] ជាឧទាហរណ៍ មតកសាសន៍ធ្វើឡើងដោយ អនីតិជនអាយុ១៥ឆ្នាំ ដូច្នេះទោះបីជាបុគ្គលនោះបានធ្វើឡើងដោយសរសេរខ្លឹមសារគ្រប់ជ្រុងជ្រោយ និងចំណុចសំខាន់តម្រូវដោយច្បាប់ក៏មតកសាសន៍នោះមិនអាចអនុវត្តបានទេ ដោយសារមតកសាសន៍នោះបង្កើតដោយបុគ្គលខ្វះសមត្ថភាព។ អ្វីដែលគួរឱ្យចាប់អារម្មណ៍នោះថា ច្បាប់អនុញ្ញាតឱ្យជនដែលស្ថិតក្រោមអាណាព្យាបាលទូទៅអាចធ្វើមតកសាសន៍បានដែរ តើអាចធ្វើដូចម្តេចបើបុគ្គលទាំងនោះមិនអាចដឹងខុសត្រូវអំពីសកម្មភាពដែលបានធ្វើផងនោះ ហើយតើត្រូវធ្វើបែបណាទើបអាចដឹងពីឆន្ទៈពិតប្រាកដបាន?

គួរឱ្យកត់សម្គាល់ថា ជននៅក្រោមអាណាព្យាបាលទូទៅក៏អាចធ្វើមតកសាសន៍ក្នុងករណីខ្លះផងដែរ។ យោងមាត្រា១១៦៨ ត្រង់កថាខណ្ឌទី២ កំណត់ថា "សិទ្ធិលុបចោលតាមបញ្ញត្តិនៃមាត្រា២៦ មិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីមតកសាសន៍"[56] ហេតុនេះករណីដែលជននៅក្រោមអាណាព្យាបាលទូទៅ ធ្វើមតកសាសន៍ដែលជាសកម្មភាពឯកតោភាគី អ្នកអាណាព្យាបាលទូទៅមិនអាចលុបចោលបានឡើយ។ ករណីនេះច្បាប់បានបញ្ជាក់អំពីបុគ្គលដែលអាចបង្កើតមតកសាសន៍បានគឺនីតិជន ដូចនេះទោះបីបុគ្គលស្ថិតនៅក្រោមហិតូបត្ថម្ភក៏

[53] សាលក្រមសាលាដំបូងរាជធានីភ្នំពេញ, លេខ១០៨ <<ភ>>ដ.រ, ១៩ មីនា ២០១៩។

[54] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា១១៥៦-១១៦៨។

[55] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា២១។

[56] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា១១៦៨(២)។

ដោយក៏អាចធ្វើមតកសាសន៍បានដែរ ដោយសារច្បាប់បានកំណត់មិនអនុញ្ញាតឱ្យមានសិទ្ធិលុបចោលតាមបញ្ញត្តិនៃមាត្រា៣០ នោះទេចំពោះករណីមតកសាសន៍។[57]

ទោះបីជាទម្រង់នៃមតកសាសន៍ជាលក្ខខណ្ឌចាំបាច់ សមត្ថភាពនាពេលធ្វើមតកសាសន៍ក៏ជាលក្ខខណ្ឌមួយសំខាន់តម្រូវដោយច្បាប់ផងដែរនៅក្នុងស្ថានភាពជាក់ស្តែង។[58] នៅពេលដែលធ្វើមតកសាសន៍ម្ចាស់បណ្តាំត្រូវមានសមត្ថភាពខាងឆន្ទៈ ប្រសិនបើម្ចាស់បណ្តាំបានធ្វើមតកសាសន៍ ក្នុងស្ថានភាពដែលខ្លួនមិនអាចយល់ដឹងវិនិច្ឆ័យអំពីលទ្ធផលតាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួនបានទេមតកសាសន៍នោះត្រូវចាត់ទុកជាមោឃៈ។ ជាឧទាហរណ៍ មតកជន ក្នុងអំឡុងពេលធ្វើមតកសាសន៍ ស្ថិតនៅក្នុងស្ថានភាព ស្រវឹងស្រាជោគជាំ ឬញៀនសារធាតុញៀនណាមួយដែលធ្វើឱ្យបាត់បង់ស្មារតីដឹងខុសត្រូវ ឬស្ថិតក្នុងស្ថានភាពវិបត្តិផ្នែកបញ្ញាស្មារតីជាអាទិ៍។ ជាហេតុមតកសាសន៍របស់មតកជនមិនអាចអនុវត្តបានទេដោយសារ ម្ចាស់បណ្តាំខ្វះស្មារតីខាងឆន្ទៈ ដែលដូចបានរៀបរាប់នៅចំណុចខាងលើ (២.២.១.២)។ ច្បាប់មិនបានរឹតត្បិតសិទ្ធិជនដែលនៅក្រោមអាណាព្យាបាលទូទៅក្នុងការបង្កើតមតកសាសន៍នោះទេ គ្រាន់តែត្រូវផ្អែកតាមមាត្រា១១៦៩ កថាខណ្ឌទី១និងកថាខណ្ឌទី២ វាក្យខណ្ឌទី១នៃក្រមរដ្ឋប្បវេណី ដោយសារ ជននៅក្រោមអាណាព្យាបាលទូទៅសន្មតថា ពុំមានសមត្ថភាពខាងឆន្ទៈ និងវិនិច្ឆ័យអំពីលទ្ធផលតាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួន នាពេលធ្វើមតកសាសន៍ ហេតុនេះ ប្រសិនបើសន្តតិជននីមួយៗអាចរកភស្តុតាងអះអាងអំពីកង្វះសមត្ថភាពរបស់ម្ចាស់បណ្តាំ នោះមតកសាសន៍នឹងត្រូវទុកជាមោឃៈ។ ទោះបីជាជនស្ថិតនៅក្រោមអាណាព្យាបាលទូទៅត្រូវបានច្បាប់កម្រិតសមត្ថភាពក៏ដោយ ការធ្វើមតកសាសន៍នៅតែអាចធ្វើបាន បើមតកសាសន៍ត្រឹមត្រូវតាមលក្ខខណ្ឌច្បាប់កំណត់។[59]

តារាង៧៖ សមត្ថភាពក្នុងការធ្វើមតកសាសន៍[60]

| ការពិពណ៌នា | សមត្ថភាពក្នុងការធ្វើមតកសាសន៍ | ផ្សេងៗ |
|---|---|---|
| នីតិជន | អាចធ្វើបាន | មាត្រា១១៦៨ |
| អនីតិជន + អគ្គាធិនភាព | អាចធ្វើបាន | មាត្រា១១៦៨ |
| ជននៅក្រោមហិតូបត្ថម្ភ | អាចធ្វើបាន | មាត្រា១១៦៨ |
| មនុស្សពិការភ្នែក | អាចធ្វើបាន | មាត្រា១១៦៨ |
| មនុស្សគថ្លង់ | អាចធ្វើបាន | មាត្រា១១៧៩ |
| ជននៅក្រោមអាណាព្យាបាលទូទៅ | អាចធ្វើបាន | មាត្រា១១៧៦ |

57 ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា១១៦៨(២)។

58 ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា១១៦៩(១)។

59 ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា១១៧៦។

60 ទេព បូផល, "សន្តតិកម្មតាមមតកសាសន៍" (ឯកសារថតចម្លងវគ្គបណ្តុះបណ្តាលជំនាន់ទី៧, ១១ មិថុនា ២០២៣)។

| | | |
|---|---|---|
| ទម្រង់តាម | | |
| ជនដែលគ្មានសមត្ថភាពខាងឆន្ទៈ | មិនអាចធ្វើបាន | មាត្រា១១៦៩ |
| អនីតិជន | មិនអាចធ្វើបាន | មាត្រា១១៦៨ |

### ២.២.២ ការប៉ះពាល់ដល់ផលប្រយោជន៍សន្តតិជន

ការមិនអនុវត្តតាមមតកសាសន៍ ដោយសារខុសលក្ខខណ្ឌទម្រង់ដែលមានចែងនៅច្បាប់ មិនមែនជាភាពស្មុគស្មាញតែមួយក្នុងការបែងចែកមត៌កតាមមតកសាសន៍នោះទេ គឺមានលក្ខខណ្ឌផ្សេងៗទៀតក្នុងការអនុវត្ត។ ចំណុចដែលគួរឱ្យកត់សម្គាល់បន្ថែមទៀតនោះគឺ ផលវិបាកក៏ដូចជាការប៉ះពាល់ដល់ចំណែកមត៌ករបស់សន្តតិជន តាមរយៈការបែងចែកមត៌កតាមមតកសាសន៍។ ការបែងចែកទ្រព្យសម្បត្តិតាមមតកសាសន៍គឺជាប្រធានបទដ៏ស្មុគស្មាញ និងមានសារៈសំខាន់មួយផ្នែកធំដូចជា ការអាចផ្តល់ឱ្យសន្តតិជននូវជំនួយហិរញ្ញវត្ថុ និងឱកាសដើម្បីទទួលបានស្ថិរភាពហិរញ្ញវត្ថុកាន់តែប្រសើរ។ មិនតែប៉ុណ្ណោះក៏អាចមានសារៈសំខាន់ជាពិសេសសម្រាប់បុគ្គល ឬក្រុមគ្រួសាររបស់មតកជនដែលកំពុងជួបការលំបាកផ្នែកហិរញ្ញវត្ថុ។ មត៌កអាចផ្តល់មធ្យោបាយដើម្បីសងបំណុល ធ្វើការ វិនិយោគ ឬស្វែងរកឱកាសសិក្សា ឬវិជ្ជាជីវៈ ដែលពីមុនក្រុមគ្រួសារមតកជនមិនអាចទៅដល់បាន។ ការបង្កើតមតកសាសន៍ គឺជាការធ្វើឡើងដោយ ឆន្ទៈរបស់មតកជនដែលជាសកម្មភាពឯកតោភាគី ដូច្នេះមតកជនអាចបង្កើត ឬសរសេរខ្លឹមសារនានាដែលស្របទៅនឹងឆន្ទៈរបស់ខ្លួន ហើយគោរពតាមលក្ខខណ្ឌទម្រង់នៃច្បាប់កំណត់នោះ មតកសាសន៍នឹងមានអានុភាពអាចអនុវត្តបាន ដែលជាកត្តាជះឥទ្ធិពលផលអវិជ្ជមានមកដល់សហសន្តតិជនទាំងឡាយ ដូចជាភាពមិនសមតុល្យភាពនៃការបែងចែកទ្រព្យដែលជាមត៌ករវាងសន្តតិជន (២.២.២.១) និងការបែងចែកទ្រព្យដែលជាមត៌កទៅឱ្យតតិយជនដែលមិនមែនជាសន្តតិជន (២.២.២.២)។

#### ២.២.២.១ ការជំទាស់របស់សន្តតិជន ពីតុល្យភាពនៃការបែងចែក

ទោះបីជាការបង្កើតមតកសាសន៍ជាសកម្មភាពឯកតោភាគីក៏ច្បាប់ហាក់ដូចរឹតត្បិតសិទ្ធិ និងទំហំនៃការបែងចែកទៅឱ្យសន្តតិជនផងដែរ។ នៅក្នុងប្រទេសកម្ពុជាការបែងចែកមត៌កត្រូវបានគ្រប់គ្រងដោយក្រមរដ្ឋប្បវេណីដែលចែងយ៉ាងលំអិតអំពីច្បាប់ និងបទប្បញ្ញត្តិជាក់លាក់ទាក់ទងនឹងការបែងចែកទ្រព្យសម្បត្តិក្នុងចំណោមសន្តតិជនទាំងឡាយ ដែលចំណុចសំខាន់មួយនៃក្រមរដ្ឋប្បវេណីទាក់ទងនឹងគោលគំនិតនៃទ្រព្យបម្រុង សំដៅទៅលើចំណែកនៃទ្រព្យត្រូវបានការពារដោយស្របច្បាប់មិនអាចរំលោភបាន។ យោងតាមក្រមរដ្ឋប្បវេណីកម្ពុជា សន្តតិជនទាំងឡាយដែលមានសិទ្ធិបែងចែកមត៌ក មានសិទ្ធិទទួលបានចំណែកបម្រុងនៃមត៌កស្គាល់ថាជា "ភាគបម្រុង"។ ភាគបម្រុង អាចមានអត្ថន័យច្រើនសម្រាប់ក្នុងការស្វែងយល់ វាអាចសំដៅចំនួនអប្បបរមានៃទ្រព្យសម្បត្តិដែលត្រូវបានច្បាប់បម្រុងទុកសម្រាប់សន្តតិជនជាកំណត់ ដែលពួកគេអាចទាមទារពីជនណាក៏ដោយដែលកាន់កាប់កម្មវត្ថុនោះក្នុងគោលបំណងដើម្បីធានានិរន្តរភាពនៃអ្នកជំនាន់ក្រោយ។[61] បើអត្ថន័យច្បាប់គឺជា "ភាគនៃ

[61] ស៊ិន ច័ន្ទផល្លុន, "ភាគបម្រុង" (ឯកសារថតចម្លងវគ្គបណ្តុះបណ្តាលជំនាន់ទី៧, ៩ កក្កដា ២០២៣)។

ទ្រព្យសម្បត្តិរបស់មតកជន ដែលបច្ចាញាតិផ្ទាល់ ឬឪពុក ម្ដាយ ឬជីដូន ជីតា និងសហព័ទ្ធរបស់មតកជននោះ អាចទាមទារបាន តាមការកំណត់របស់ច្បាប់។[62] នេះមានន័យថាទ្រព្យសម្បត្តិរបស់បុគ្គលដែលបានទទួលមរណភាពមិនអាចត្រូវបានបែងចែកតាមរបៀបដែលបំពានសិទ្ធិនៃសន្តតិជនរបស់ពួកគេក្នុងការទទួលបានចំណែកណាមួយក្រោមអប្បបរមាជាក់លាក់នៃមត៌កនោះទេ។ ផ្នែកដែលបានបម្រុងទុកត្រូវបានគណនាដោយផ្អែកលើចំនួនកូនចៅ និងសមាមាត្ររៀងៗខ្លួន ដូចមានចែងក្នុងច្បាប់។[63]

ទោះបីជាមានការចែងដោយច្បាប់ក្នុងការកំណត់ និងការរឹតត្បិតទៅលើមតកជន ក្នុងការសរសេរបែងចែកមត៌កក៏មាននៅមានភាពស្មុគស្មាញក្នុងការដោះស្រាយច្រើននៅក្នុងសង្គមជាញឹកញាប់។ ទស្សនៈជាច្រើនបានលើកឡើងថា ទ្រព្យជារបស់មតកជនដូចនេះសិទ្ធិទាំងអស់គឺសម្រេចលើ ម្ចាស់បណ្ដាំ ដោយមានសិទ្ធិពេញលេញក្នុងការបែងចែកឱ្យទៅសន្តតិជនណាម្នាក់ ហេតុអ្វីច្បាប់រឹតត្បិត និងកំណត់អប្បបរមាអំពីនៃមត៌កទៅឱ្យសន្តតិជន? ការត្រូវបានបំពានសិទ្ធិលើភាគបម្រុងចំនួនអប្បបរមាដល់សន្តតិជនអាចកើតឡើងនៅពេលដែលឆន្ទៈបុគ្គលដែលបានស្លាប់ ឬការរៀបចំធ្វើមតកសាសន៍បែងចែកចំណែកមិនសមគុល្យនៃទ្រព្យសម្បត្តិដល់សហសន្តតិជនខណៈពេលដែលមតកជនបានយកទ្រព្យសម្បត្តិដែលជាកម្មវត្ថុនៃការបែងចែកមត៌ក ប្រគល់ឱ្យសហសន្តតិជនណាម្នាក់ចំនួនច្រើនលើសលប់ឬមិនបានប្រគល់ទ្រព្យសម្បត្តិណាមួយសោះទៅឱ្យសន្តតិជនណាម្នាក់ទៀតដែលកើតឡើងសភាពកាត់បន្ថយទ្រព្យបម្រុងរបស់សន្តតិជន។

ការយល់ច្បាស់ពីភាគបម្រុងមានសារៈសំខាន់ក្នុងការបង្កើតមតកសាសន៍។ ទាំងបច្ចាញាតិផ្ទាល់ដែលជា សន្តតិជនជំនាន់ក្រោយ មានកូន ចៅ និងបុព្វញាតិខ្សែផ្ទាល់មាន ឪពុកម្ដាយ ឬជីដូនជីតា និងសហព័ទ្ធរបស់មតកជនសុទ្ធតែមានសិទ្ធិលើភាគបម្រុងជាចំនួនអប្បបរមាមួយដែលច្បាប់កំណត់។[64] ប្រសិនបើសន្តតិជនជាឪពុកម្ដាយ ឬជីដូន ជីតា ទ្រព្យដែលជាសិទ្ធិលើភាគបម្រុងនោះគឺ ចំនួន ១ភាគ៣ នៃទ្រព្យសម្បត្តិរបស់មតកជន[65] ប្រសិនក្នុងករណីផ្សេងក្រៅពីសន្តតិជនជា ឪពុកម្ដាយ ឬជីដូន ជីតា ទ្រព្យដែលជាសិទ្ធិលើភាគបម្រុងគឺចំនួន ១ ភាគ២ នៃទ្រព្យសម្បត្តិរបស់មតកជន។[66] ដូច្នេះហើយប្រសិនបើមានការបំពានណាមួយកើតឡើងវាគឺជាភាគស្មុគស្មាញមួយដើម្បីដោះស្រាយ។

តារាង៨៖ ដំណាក់កាលនៃការគណនាភាគបម្រុង

| ដំណាក់កាល | ពិពណ៌នា |
|---|---|
| ១ | ស្វែងរកទ្រព្យសម្បត្តិជាមូលដ្ឋាន |

62 ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, សទ្ធានុក្រមផ្នែករដ្ឋប្បវេណី។
63 ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា១២៣០។
64 ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា១២៣០។
65 ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា១២៣០(១ក)។
66 ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា១២៣០(១ខ)។

| | |
|---|---|
| ២ | រកសិទ្ធិលើភាគបម្រុងសរុប |
| ៣ | រកចំនួនសិទ្ធិលើភាគបម្រុងរបស់សន្តតិជននីមួយៗ |
| ៤ | ស្វែងរកចំនួនទឹកប្រាក់នៃការកាត់បន្ថយ |
| ៥ | ការកាត់បន្ថយតាមលំដាប់ |

ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ លើកឡើងអំពីរបៀបនៃការគណនាដោយយកទ្រព្យសម្បត្តិដែលមតកជនមាននៅពេលចាប់ផ្តើមធ្វើសន្តតិកម្ម បូកតម្លៃនៃផលប្រយោជន៍ពិសេស និងតម្លៃនៃទ្រព្យសម្បត្តិប្រទានកម្មហើយដកនូវចំនួនប្រាក់សរុបនៃកាតព្វកិច្ច[67]ចេញ។ ចុះអ្វីទៅផលប្រយោជន៍ពិសេស និងអ្វីទៅជាតម្លៃនៃទ្រព្យសម្បត្តិប្រទានកម្ម? ផលប្រយោជន៍ពិសេសសំដៅលើប្រទានកម្មដែលមតកជនបានធ្វើចំពោះសន្តតិជននីមួយៗកាលនៅរស់។ ផលប្រយោជន៍ពិសេសនៅក្នុងន័យនេះពុំរាប់បញ្ចូលនូវអច្ច័យទានដែលមតកជនបានធ្វើតាមមតកសាសន៍ឡើយ។ [68] ប្រទានកម្មសំដៅលើអំណោយដែលមតកជនបានធ្វើកាលនៅរស់ឱ្យទៅតតិយជនឬអាចហៅម្យ៉ាងទៀតថាជាជនក្រៅពីសន្តតិជន ក្នុងអំឡុងពេល១ឆ្នាំមុនពេលចាប់ផ្តើមសន្តតិកម្មឬពេលដឹងថាបំពានភាគបម្រុង។ [69] ការគណនាដែលចែងនៅក្នុងមាត្រា១២៣១ នៃក្រមរដ្ឋប្បវេណី គឺដើម្បីស្វែងរកនូវទ្រព្យសម្បត្តិជាមូលដ្ឋានដែលជាទ្រព្យសកម្មរបស់មតកជនមានគិតត្រឹមពេលចាប់ផ្តើមសន្តតិកម្ម ហើយជារបៀបនៃការស្វែងរកបន្តទៅដំណាក់កាលផ្សេងៗទៀតដើម្បីឈានទៅរកបាននូវភាគបម្រុងរបស់សន្តតិជនម្នាក់ៗដែលជានីតិវិធីដំណាក់កាលទី១ ដូចមានលើកឡើងនៅតារាង៨ ខាងលើ។

តារាង៩៖ រូបមន្តនៃការគណនាទ្រព្យសម្បត្តិជាមូលដ្ឋាន[70]

| ទ្រព្យសម្បត្តិជាមូលដ្ឋាន |
|---|
| ទ្រព្យពេលចាប់ផ្តើមសន្តតិកម្ម + ផលប្រយោជន៍ + ប្រទានកម្ម ១២៣២ - កាតព្វកិច្ច |

បន្ទាប់ពីស្វែងរកទ្រព្យសម្បត្តិជាមូលដ្ឋាន សិទ្ធិលើភាគបម្រុងសរុបបន្តអនុវត្ត ការដែលអាចដឹងបានថាភាគបម្រុងសរុបមានចំនួនប៉ុន្មាន គឺត្រូវយកចំនួន ទ្រព្យសម្បត្តិជាមូលដ្ឋានរកឃើញនៅដំណាក់កាលទី១ មកគុណនឹង ១ភាគ២ ឬ១ភាគ៣។[71] ការគុណនឹងប្រភាគ ១ភាគ២ និង ១ភាគ៣ អាស្រ័យលើ សន្តតិជនដែលចូលរួមក្នុងការចែកមត៌ក ដោយក្នុងករណីដែលសន្តតិជនមិនមែនជា ឪពុកម្តាយ ឬជីដូនជីតា ត្រូវយកទ្រព្យជាមូលដ្ឋាន

[67] សំដៅលើតម្លៃសរុបនៃកាតព្វកិច្ចដែលមតកជនមានចំពោះតតិយជន។

[68] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា១១៦៣។

[69] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា១២៣២។

[70] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា១២៣១។

[71] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា១២៣០(១)។

គុណនឹង ១ភាគ២ ហើយបើក្នុងករណីដែលសន្តតិជនគឺជា ឪពុកម្តាយ ឬជីដូនជីតា វិញត្រូវគុណនឹង ១ភាគ៣។[72] ជាក់ស្តែងនៅពេលដែលរកឃើញសិទ្ធិលើភាគបម្រុងសរុបរួចមក ត្រូវយកទៅគុណនឹងចំណែកមត៌ករបស់សន្តតិជនដើម្បីស្វែងរកសិទ្ធិលើភាគបម្រុងរបស់សន្តតិជននីមួយៗដែលខំស្វែងរកតាំងពីដើមមក។[73] ប្រសិនបើក្នុងករណីមានការបែងចែកណាមួយ និងការចែងនៅក្នុងមតកសាសន៍ដែលធ្វើឡើងដោយមតកជន ដែលផ្តល់ឱ្យសន្តតិជនណាម្នាក់ច្រើនលើសលប់ហើយបំពាននូវភាគបម្រុង របស់សន្តតិជនផ្សេងៗទៀតដែលត្រូវបានគណនាក្នុងដំណាក់ទី៣ ខាងលើតាមការបកស្រាយនោះ ជម្លោះវិវាទនឹងកើតឡើងដោយខានពុំបានរវាងសន្តតិជន និងសន្តតិជន។ ក្នុងករណីបែបនេះ សន្តតិជនដែលត្រូវបានរំលោភដោយភាគបម្រុង ច្បាស់ណាស់នឹងអាចស្វែងរកជំនួយផ្លូវច្បាប់ដើម្បីទាមទារនិងជំទាស់នឹងការបែងចែកតាមមតកសាសន៍នោះ។[74] ក្រមរដ្ឋប្បវេណីបានផ្តល់យន្តការសម្រាប់សន្តតិជនទាំងនេះដើម្បីអះអាងនិងផ្តល់អំពីសិទ្ធិរបស់ជនទាំងនោះ ជៀសវាងការបែងចែកដោយ អយុត្តិធម៌។

គោលគំនិតនៃទ្រព្យដែលបានបម្រុងទុកមិនមានតែប្រទេសកម្ពុជានោះទេ ជាទូទៅនៅក្នុងយុត្តាធិការនៃច្បាប់ផ្សេងៗដែលប្រកាន់យកប្រព័ន្ធច្បាប់ស៊ីវិលក្នុងនោះប្រទេសអេស្ប៉ាញមានកំណត់នូវផ្នែក នៃអចលនទ្រព្យបម្រុងទុកសម្រាប់សន្តតិជនដែលជាកូនចៅ[75] រីឯទ្វីបអាស៊ី ប្រទេសជប៉ុន និងប្រទេសកូរ៉េខាងត្បូង សុទ្ធតែមានច្បាប់ចែងអំពីចំណែកដែលបម្រុងទុក សម្រាប់កូនចៅជាសន្តតិជន ដើម្បីធានាបាននូវចំណែកនៃទ្រព្យបានទៅដល់សន្តតិជន។[76] បទប្បញ្ញត្តិនៃក្រមរដ្ឋប្បវេណីកម្ពុជាលើបញ្ហានេះមានគោលបំណងការពារផលប្រយោជន៍ស្របច្បាប់របស់កូនចៅ ជំនាន់ក្រោយដែលជាសន្តតិជន។

### ២.២.២.២ ការបែងចែកអច្ច័យទានឱ្យតតិយជនដែលប៉ះពាល់ដល់សន្តតិជន

ការប៉ះពាល់ដល់ចំណែកភាគបម្រុងរបស់សហសន្តតិជន មិនមែនដោយសារហេតុផលនៃការបែងចែកមិនតុល្យភាពដល់សហសន្តតិជន ដូចពិភាក្សានៅចំណុច ២.២.២.១ មួយនោះឡើយ។ ការបែងចែកទ្រព្យដែលជាមត៌កធ្វើឡើងដោយមតកជនតាមរយៈមតកសាសន៍គឺអាចធ្វើបានគ្រប់ទម្រង់នៃខ្លឹមសារតាមឆន្ទៈរបស់មតកជន ដោយក្នុងនាមជាម្ចាស់ទ្រព្យសម្បត្តិមានសិទ្ធិក្នុងការចាត់ចែងទៅឱ្យសន្តតិជនណាមួយ ឬតតិយជនណាមួយគ្រាន់តែការបែងចែកទ្រព្យសម្បត្តិទៅឱ្យតតិយជនណាម្នាក់ក្រៅពីសន្តតិជននៅក្នុងមតកសាសន៍គឺអច្ច័យទាន។[77] ប្រទានកម្មដែលម្ចាស់បណ្តាំធ្វើឱ្យទៅមនុស្សម្នាក់ ឬច្រើននាក់នូវទ្រព្យសម្បត្តិខ្លួន តាមរយៈមតកសាសន៍។ អច្ច័យទានតាមរយៈការចែងដោយច្បាប់មាន ២ប្រភេទផ្សេងៗទៀតគឺ អច្ច័យទានមានកំណត់ និងអច្ច័យទានសកល។

[72] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា១២៣០(១)។
[73] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា១២៣០(២-៣)។
[74] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា១២៣៥។
[75] ភាគបម្រុងច្បាប់ ប្រទេសអេស្ប៉ាញ។
[76] ភាគបម្រុងច្បាប់ ប្រទេសជប៉ុន និងប្រទេសកូរ៉េខាងត្បូង។
[77] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា១១៩៩។

អច្ច័យទានសកល គឺជាប្រទានកម្មដែលម្ចាស់បណ្ដាំធ្វើទៅឱ្យមនុស្សម្នាក់ ឬច្រើននាក់ នូវទ្រព្យសម្បត្តិទាំងអស់ ឬមួយផ្នែកដែលកំណត់ទៅតាមភាគ រីឯអច្ច័យទានមានកំណត់ គឺជាប្រទានកម្មដែលកំណត់ទ្រព្យសម្បត្តិជាក់លាក់ទៅឱ្យមនុស្សម្នាក់ ឬច្រើននាក់ដោយមតកសាសន៍។[78]

តារាង១០៖ ប្រភេទនៃអច្ច័យទាន[79]

| ប្រភេទ | ពិពណ៌នា |
|---|---|
| អច្ច័យទានមានកំណត់ | ប្រទានកម្មដែលកំណត់ទ្រព្យសម្បត្តិជាក់លាក់ ទៅឱ្យមនុស្សម្នាក់ ឬច្រើននាក់ដោយមតកសាសន៍។ |
| អច្ច័យទានសកល | ប្រទានកម្មដែលម្ចាស់បណ្ដាំធ្វើទៅឱ្យមនុស្សម្នាក់ ឬច្រើននាក់នូវទ្រព្យសម្បត្តិទាំងអស់ ឬមួយផ្នែកដែលកំណត់ទៅតាមភាគ ដោយមតកសាសន៍។ |

នៅពេលមតកជនបានសរសេរខ្លឹមសារ ក្នុងការប្រគល់ទ្រព្យណាមួយទៅឱ្យជនណាម្នាក់ក្រៅពីសន្តតិជន នោះនឹងធ្វើឱ្យមានការប៉ះពាល់ទៅដល់សន្តតិជនផ្សេងទៀត។ ជាធម្មតា តតិយជនមិនមានសិទ្ធិក្នុងការទទួលបានការបែងចែកមត៌កទេ ដោយសារច្បាប់តម្រូវតែ សន្តតិជនប៉ុណ្ណោះទើបអាចបែងចែកបាន លុះត្រាតែមានប្រទានកម្មធ្វើឡើងតាមមតកសាសន៍ដោយមតកជន។

[78] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា១១៩៩។

[79] ង៉ី ភីរក្ស, "អច្ច័យទាន" (ឯកសារចតចម្លងវគ្គបណ្ដុះបណ្ដាលជំនាន់ទី៧, ២០២៣)។

# ជំពូកទី៣

# បញ្ហាប្រឈមនៃសន្តិកម្មតាមមតកសាសន៍

# ជំពូកទី៣
# បញ្ហាប្រឈមនៃសន្តតិកម្មតាមមតកសាសន៍

## ៣.១ កង្វះការយល់ដឹងស៊ីជម្រៅលើសន្តតិកម្មតាមមតកសាសន៍របស់អ្នកវិជ្ជាជីវៈ

ទោះបីជាការបែងចែកមត៌កតាមមតកសាសន៍ជាវិធីម្យ៉ាងមានភាពងាយស្រួល និងជៀសវាងពីភាពស្មុគស្មាញដោយការបែងចែកតាមច្បាប់នៅតុលាការ ក៏ហាក់ដូចជាមានបញ្ហាច្រើនកើតឡើងដែលជាផលវិបាក។ តាមរយៈការបង្កើតជាលិខិត និងសរសេរខ្លឹមសារដែលជាឆន្ទៈរបស់មតកជនស្តាប់មកមានភាពងាយស្រួលតែផលវិបាកអាចកើតឡើងជាច្រើនក្នុងការអនុវត្តផងដែរ ដោយសារតែការខ្វះសមត្ថភាពយល់ដឹងពីចំណេះដឹងបទពិសោធន៍របស់សំណាក់ភាគីដែលពាក់ព័ន្ធ។ ជាក់ស្តែងការបង្កើត ឬការអនុវត្តមតកសាសន៍មានភាពស្មុគស្មាញដែលធ្វើឱ្យប្រជាពលរដ្ឋអាចនឹងមិនមានភាពយល់ដឹង ទើបរាល់សកម្មភាពនៃការបង្កើតមតកសាសន៍និងសកម្មភាពនានាតម្រូវឱ្យអ្នកច្បាប់ជួយចង្អុលបង្ហាញ។ អ្វីដែលគួរឱ្យកត់សម្គាល់គឺអ្នកច្បាប់ដែលមានភារៈកិច្ចជួយសម្រួលកិច្ចការផ្នែកសន្តតិកម្មតាមមតកសាសន៍មានការខ្វះភាពយល់ដឹងស៊ីជម្រៅខ្លាំង ធ្វើឱ្យមានផលប៉ះពាល់ដល់ក្រុមគ្រួសារមតកជនដែលជាសន្តតិជន និងប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់ឆន្ទៈរបស់មតកជន។

ការធ្វើមតកសាសន៍តាមរយៈការចែងក្នុងក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ បានអនុញ្ញាតឱ្យមកតជនផ្ទាល់អាចតាក់តែងដោយខ្លួនឯងនូវមតកសាសន៍។ ទោះបីជាមានការចែងលក្ខខណ្ឌក្នុងការបង្កើតមតកសាសន៍ក្នុងក្រមរដ្ឋប្បវេណីប្រជាពលរដ្ឋនៅតែមិនមានការយល់ដឹងផ្នែកច្បាប់គ្រប់គ្រាន់ពីទម្រង់ឬការបង្កើតមតកសាសន៍របស់ខ្លួនឱ្យមានភាពត្រឹមត្រូវឬមានការព្រួយបារម្ភអំពីសុពលភាព ឬការមិនអាចអនុវត្តបានទៅថ្ងៃអនាគត ទើបគោលគំនិតរបស់ប្រជាជនក្នុងសង្គម ពឹងផ្អែកទៅលើសេវាកម្មរបស់អ្នកវិជ្ជាជីវៈច្បាប់ដើម្បីជួយសម្រួលក្នុងការតាក់តែង។ នាពេលបច្ចុប្បន្ន អ្នកវិជ្ជាជីវៈច្បាប់ដែលប្រជាជនស្គាល់ភាគច្រើននោះគឺមេធាវី។ ការព្រួយបារម្ភនៅតែកើតមានឡើងដោយសារ មេធាវីមួយចំនួនមានភាពមិនច្បាស់លាស់ក្នុងការយល់ដឹងពីមតកសាសន៍។ ជាក់ស្តែងមតកសាសន៍នានាមិនមែនសុទ្ធតែអាចឱ្យមេធាវីតាក់តែងបាននោះទេ ការជួយមតកជនក្នុងការតាក់តែងធ្វើឱ្យបាត់បង់សុពលភាពនៃមតកសាសន៍។ ទម្រង់មតកសាសន៍ធម្មតាទាំងបីគឺមេធាវីអាចជួយមតកជនក្នុងការតាក់តែងបាន តែមតកសាសន៍ប្រភេទលិខិតសម្ងាត់ប៉ុណ្ណោះ ដោយច្បាប់មិនបានបញ្ជាក់ច្បាស់ថាមេធាវីមានសិទ្ធិនោះទេ តែក៏មិនបានហាមឃាត់បុគ្គលណាម្នាក់ជួយសម្រួលក្នុងការតាក់តែងផងដែរ។[80] នៅក្នុងសង្គមបច្ចុប្បន្នឃើញថា មេធាវីមានការយល់ច្រឡំអំពីតួនាទីរបស់ខ្លួនដោយជួយមតកជនតាក់តែងប្រភេទមតកសាសន៍ដោយលិខិតឯកជន និងលិខិតយថាភូត ជាប្រភេទមតកសាសន៍ដែលខ្លួនគ្មានសិទ្ធិក្នុងការបង្កើត និងធ្វើឱ្យមតកសាសន៍បាត់បង់សុពលភាព[81] បើទោះបីជារាល់អត្ថន័យនៅក្នុងមតកសាសន៍សុទ្ធតែជាឆន្ទៈដោយផ្ទាល់របស់មតកសាសន៍ក៏ដោយ មិនអាចអនុវត្ត

[80] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា១១៧៥។

[81] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា១១៧៣-១១៧៤។

បាននៅពេលខាងមុខ។[82] មួយវិញទៀតក្នុងកាលៈទេសៈខ្លះមេធាវីបានបំពេញតួនាទីរបស់ខ្លួនបានល្អដោយជួយមតកជនតាក់តែងមតកសាសន៍តាមប្រភេទត្រឹមត្រូវក្នុងទម្រង់មតកសាសន៍ដោយលិខិតសម្ងាត់ ប៉ុន្តែបានធ្វើខុសទៅនឹងលក្ខខណ្ឌទម្រង់ដែលច្បាប់តម្រូវដូចជា មតកសាសន៍ដោយលិខិតសម្ងាត់ ម្ចាស់បណ្តាំត្រូវចុះហត្ថលេខាលើលិខិតនោះ តែមេធាវីបែរជាឱ្យមតកជនផ្តិតស្នាមម្រាមដៃទៅវិញ ដែលធ្វើឱ្យមតកសាសន៍មិនមានសុពលភាពក្នុងការអនុវត្ត។[83]

ចំពោះវិជ្ជាជីវៈសារការីវិញដែលជា តួនាទីមួយជួយសម្រួលដល់មតកជនក្នុងការបង្កើតមតកសាសន៍ ប៉ុន្តែវិជ្ជាជីវៈនេះមិនសូវជាមានប្រជាពលរដ្ឋដឹង និងស្គាល់នោះទេដោយសារតែសារការីមានលក្ខណៈថ្មីខុសពីមេធាវីដែលប្រជាជនទាំងអស់មានការស្គាល់និងដឹងច្រើន។ តួនាទីជាសារការី ជាតួនាទីមួយដែលច្បាប់តម្រូវធ្វើលិខិតបទដ្ឋានគតិយុត្តផ្សេងៗ មតកសាសន៍ក៏ដូចគ្នាការធ្វើមតកសាសន៍ដែលមានចែងនៅក្នុងក្រមរដ្ឋប្បវេណីគឺជា ភារៈកិច្ចរបស់សារការី។[84] ទម្រង់ធម្មតានៃមតកសាសន៍ទាំងបីមានតែមតកសាសន៍ធ្វើឡើងដោយលិខិតឯកជនប៉ុណ្ណោះដែលមិនអាចធ្វើឡើងដោយសារការី គឺតម្រូវឱ្យមតកជនផ្ទាល់ជាអ្នកបង្កើតដោយខ្លួនឯង។[85] ទោះបីជាសារការីជាវិជ្ជាជីវៈមួយដែលមានជំនាញក្នុងការបង្កើតលិខិតមតកសាសន៍ក៏ដោយ ក៏មានបុគ្គលមួយចំនួនតូចខ្វះសមត្ថភាពក្នុងការយល់ដឹងបង្កើត និងភ័ន្តច្រឡំធ្វើឱ្យមានការខូចខាតដល់ការអនុវត្តនៃមតកសាសន៍ ដែលជាឆន្ទៈរបស់មតកជនផងដែរ។ នាពេលបច្ចុប្បន្ន មានរឿងក្តីជាច្រើនឈានទៅដល់ការដោះស្រាយនៅតុលាការទាក់ទងទៅនឹងការបែងចែកមត៌កតាមមតកសាសន៍ដែលខុសទម្រង់ផ្សេងៗ។ ការបង្កើតមតកសាសន៍ដោយខុសទម្រង់ទាំងនេះ អាចឃើញជាញឹកញាប់គឺលក្ខខណ្ឌចាំបាច់ដែលកំណត់ដោយច្បាប់ដើម្បីធ្វើឱ្យមតកសាសន៍មានសុពលភាព។ ដូចជាបើមតកសាសន៍ដោយលិខិតយថាភូត សារការីត្រូវសរសេរនូវអត្ថន័យនៃមតកសាសន៍របស់ម្ចាស់បណ្តាំនោះ ជាលាយលក្ខណ៍អក្សរ ហើយត្រូវសូត្រឱ្យម្ចាស់បណ្តាំ និងសាក្សីស្តាប់[86] ប៉ុន្តែសារការីបែរជា សរសេរខ្លឹមសារនៃមតកសាសន៍នោះក្នុងកុំព្យូទ័រទៅវិញដែលខុសទៅនឹងលក្ខខណ្ឌទម្រង់ធ្វើឱ្យមតកសាសន៍មិនអាចអនុវត្តបាននៅថ្ងៃខាងមុខ។ ម្យ៉ាងវិញទៀតប្រសិនបើមតកសាសន៍ធ្វើឡើងដោយលិខិតសម្ងាត់ សារការីត្រូវចុះហត្ថលេខាលើលិខិតដែលម្ចាស់បណ្តាំនោះប្រគល់ឱ្យជាមួយគ្នានឹងសាក្សីនិងម្ចាស់បណ្តាំ[87] ក៏ប៉ុន្តែសារការីមានការភ័ន្តច្រឡំដោយឱ្យសាក្សី និងម្ចាស់បណ្តាំផ្តិត ម្រាមដៃទៅវិញ។ បញ្ហាផ្សេងទៀតដូចជាទាក់ទងនឹងចំនួននិងសមត្ថភាពរបស់សាក្សី។ល។ ទង្វើទាំងអស់នេះគឺជាការខ្វះភាពយល់ដឹង និងសមត្ថភាពក្នុងការបង្កើតមតកសាសន៍របស់

[82] បទសម្ភាសជាមួយនឹងទីប្រឹក្សាច្បាប់នៃក្រុមហ៊ុនមេធាវីខ្មែរអប្សរា, ២៨ សីហា ២០២៤។

[83] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា១១៧៥។

[84] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា១១៧៣-១១៧៥។

[85] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា១១៧៤។

[86] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា១១៧៣(២គ)។

[87] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា១១៧៥(១ឃ)។

សារការី ដែលធ្វើឱ្យប៉ះពាល់ផលប្រយោជន៍ទៅដល់មតកជន និងសន្តតិជនទាំងអស់នាថ្ងៃខាងមុខដែលជាបញ្ហាប្រឈមខ្លាំងគួរឱ្យព្រួយបារម្ភ។

ទោះបីជាមានការជួយជ្រោមជ្រែងពីអ្នកវិជ្ជាជីវៈ ដើម្បីបង្កើតបានមតកសាសន៍មួយត្រឹមត្រូវតាមច្បាប់ក៏នៅតែមានបញ្ហាស្មុគស្មាញខ្លះនៅក្នុងនីតិវិធីនៃការបែងចែកមត៌កផងដែរ។ ភាគីពាក់ព័ន្ធមួយទៀតដែល ជាបុគ្គលជាប់ពាក់ព័ន្ធខ្លាំងនៅក្នុងការបែងចែកមត៌កតាមមតកសាសន៍នោះគឺ មន្ត្រីសុរិយោដី។ បន្ទាប់ពីពិភាក្សា អំពីការបែងចែកមត៌កតាមមតកសាសន៍ និងលក្ខខណ្ឌដើម្បីឱ្យមតកសាសន៍មានសុពលភាពផ្នែកខាងក្រោមនេះនឹងពិភាក្សាអំពីនីតិវិធីនៃការបែងចែក។ លទ្ធកម្មតាមសន្តតិកម្ម គឺជាការផ្ទេរសិទ្ធិនៃទ្រព្យសម្បត្តិពីបុគ្គលដែលស្លាប់មកបុគ្គលនៅមានជីវិត រួមមានសន្តតិជន ឬអច្ច័យលាភី។ សន្តតិកម្មអាចអនុវត្តទៅលើទ្រព្យ កាន់កាប់ជាក់ស្ដែងមិនទាន់បានចុះបញ្ជី ឬមិនមានលិខិតរដ្ឋបាលបញ្ជាក់។ ករណីមានសន្តតិជនច្រើននាក់ សហសន្តតិជនម្នាក់ៗបន្តសិទ្ធិនិងករណីយកិច្ចតាមសមាមាត្រនៃចំណែករៀងខ្លួន។ ជាគោលការណ៍ការធ្វើលទ្ធកម្មកម្មសិទ្ធិដោយមូលហេតុសន្តតិកម្ម នឹងមានអានុភាពបន្ទាប់ពីជនដែលសន្មតថាជាមតកជនបានទទួលមរណភាព ហើយសិទ្ធិនិងកាតព្វកិច្ចក្រោមទ្រព្យសម្បត្តិរបស់មតកជនត្រូវធ្លាក់មកសន្តតិជនដោយស្វ័យប្រវត្តិ។ សហសន្តតិជនដែលបានទទួលបន្តនូវសិទ្ធិ និងកាតព្វកិច្ចចំពោះទ្រព្យសម្បត្តិ មានសិទ្ធិពេញលេញក្នុងការគ្រប់គ្រងចាត់ចែង ប្រើប្រាស់ និងអាស្រ័យផល។ ចំពោះទ្រព្យសម្បត្តិជាអចលនវត្ថុមានការលំបាកក្នុងការបង្ហាញជាសាធារណៈចំពោះតតិយជនថាសន្តតិជនណាមួយជាម្ចាស់កម្មសិទ្ធិពិតប្រាកដលើអចលនវត្ថុនោះតាមលក្ខណៈបច្ចេកទេស នាំឱ្យមានការចុះបញ្ជីផ្ទេរកម្មសិទ្ធិអចលនវត្ថុ ដោយមូលហេតុសន្តតិកម្មនៅរដ្ឋបាលសុរិយោដីលើប័ណ្ណកម្មសិទ្ធិ។ ដូចនេះដើម្បីឱ្យការចុះបញ្ជីទទួលបានជោគជ័យ អ្នកស្នើសុំចុះបញ្ជីត្រូវឆ្លងកាត់ដំណាក់កាលមួយចំនួន គឺដំណាក់កាលមុនចុះបញ្ជីដែលធ្វើឡើងដោយអ្នកស្នើសុំចុះបញ្ជីដូចបានបង្ហាញនៅតារាងខាងក្រោម។

តារាង១១៖ ដំណាក់កាលមុនការចុះបញ្ជី



តារាងខាងលើគឺជា នីតិវិធីរបស់សន្តតិជន ឬអ្នកមានសិទ្ធិចុះបញ្ជីកម្មសិទ្ធិ ដែលត្រូវត្រៀម ឬសកម្មភាពផ្សេងៗមុខពេលចុះបញ្ជីដោយភារៈកិច្ចធ្លាក់លើជនទាំងឡាយណាដែលមានសិទ្ធិក្នុងការ រៀបចំទាំងនោះរួមមានដូចជា កូន, ចៅដែលជាសន្តតិជនឬជនដែលទទួលបានផលប្រយោជន៍ពីការចុះបញ្ជីនេះ។ ខាងក្រោមនេះជាតារាងឧទាហរណ៍បង្ហាញអំពីបុគ្គលដែលជាសន្តតិជន ឬជាជនមានសិទ្ធិចុះបញ្ជីកម្មសិទ្ធិ នៅរដ្ឋបាលសុរិយោដី។

តារាង១២៖ អ្នកមានសិទ្ធិចុះបញ្ជី និងកន្លែងដាក់ពាក្យស្នើសុំ[88]




តាមរយៈតារាងខាងលើ "ក" គឺជាមតកជនដែលបានទទួលមរណភាព ហើយបន្សល់ទុកមតកសាសន៍នូវដីមួយកន្លែងមកឱ្យកូន ៣នាក់ មាន "ខ" "គ" និង "ឃ" ។ ដូច្នេះ ខ, គ និង ឃ ជាជនមានសិទ្ធិចុះបញ្ជីនៅរដ្ឋបាលសុរិយោដី។[89]

នីតិវិធីនៃការចុះបញ្ជីអចលនវត្ថុ ដោយសន្តតិកម្ម មានភាពស្មុគស្មាញនិងពិបាករួចទៅហើយ អ្វីដែលគួរឱ្យបារម្ភ និងកើតឡើងរួចមកហើយនោះគឺមន្ត្រីមួយចំនួនដែលកាន់ការងារចុះបញ្ជីបានបង្កើនបញ្ហា ដើម្បីដោះស្រាយបញ្ហាជាហេតុធ្វើឱ្យករណីដោះស្រាយមានការអូសបន្លាយដើម្បីបានផលប្រយោជន៍ពីភាគីពាក់ព័ន្ធ។ [90] ដូច្នេះទើបបញ្ហានេះជារនាំងទប់ស្កាត់ល្បឿននៃការដោះស្រាយបញ្ហាប្រឈម និងផលលំបាកសម្រាប់សន្តតិជនដែលពាក់ព័ន្ធក្នុងរឿងនេះ។ ទាំងដែលការចុះបញ្ជីផ្ទេរកម្មសិទ្ធិអចលនវត្ថុដោយមូលហេតុសន្តតិកម្ម គឺជាមធ្យោបាយមួយ

[88] អ៊ីវ ប៉ូលី និង ទេព បូផល, "ការចុះបញ្ជីផ្ទេរកម្មសិទ្ធិលើអចលនវត្ថុដោយមូលហេតុសន្តតិកម្ម" ៤ វិច្ឆិកា ២០១៨។

[89] ប្រកាសអន្តរក្រសួងរបស់ក្រសួងយុត្តិធម៌ និងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ស្តីពីនីតិវិធីនៃការចុះបញ្ជីអំពីសិទ្ធិប្រត្យក្សទាក់ទងនឹងក្រមរដ្ឋប្បវេណី, លេខ៣០អយជនស/ប្រក/១៣, ២៩ មករា ២០១៣, ប្រការ១០។

[90] បទសម្ភាសផ្ទាល់ខ្លួនជាមួយប្រជាពលរដ្ឋរស់នៅខណ្ឌដង្កោ (បទសម្ភាសត្រូវបានធ្វើឡើងដោយសម្ងាត់), ១២ តុលា ២០០៩។

ដែលនាំឱ្យសន្តតិជនមានភាពងាយស្រួលក្នុងការធ្វើអនុប្បទានទ្រព្យ ឬដាក់ប្រាតិភោគនូវទ្រព្យរបស់ខ្លួនទៅឱ្យតតិយជន ទៅជាមានភាពលំបាកមួយដែលសន្តតិជនមានការព្រួយបារម្ភ។

តារាង១៣៖ ដំណាក់កាលនៃការចុះបញ្ជី




## ៣.២ កង្វះការយល់ដឹងរបស់ប្រជាជនអំពីសន្តតិកម្មតាមមតកសាសន៍

ការបន្សល់ទុកពីមួយជំនាន់ទៅមួយជំនាន់នូវរបៀប នៃការបង្កើតមតកសាសន៍តាំងពីយូរលង់ណាស់មក ហើយ បានក្លាយជាគុណវិបត្តិក្នុងការអនុវត្តនាពេលបច្ចុប្បន្ន។ ការផ្ដែផ្ដាំអំពីវិធីនៃការបែងចែកព្រមទាំង ចំណែក នៃការបែងចែកមត៌កដោយផ្ទាល់មាត់គឺបានចាក់ឫសយ៉ាងជ្រៅចូលទៅក្នុងផ្នត់គំនិតរបស់ប្រជាជនខ្មែរសព្វថ្ងៃបន្ត ពីមួយជំនាន់ទៅមួយជំនាន់។ ជាក់ស្ដែងការផ្ដែផ្ដាំដោយផ្ទាល់មាត់ពីមតកជនគឺជាវិធីសាស្ត្រនៃការបែងចែកមួយ មិនមានចែងនៅក្នុងច្បាប់នោះទេ ជាហេតុធ្វើឱ្យការបែងចែកកើតមាននូវបញ្ហាបន្ទាប់ពីមតកជនទទួលមរណភាព។ ករណីសន្តតិជននានាដែលមានសិទ្ធិក្នុងការទទួលមត៌ក ព្រមព្រៀងស្រុះស្រួលក្នុងការបែងចែកតាមបណ្ដាំផ្ទាល់ មាត់ពីមតកជន ហាក់ដូចជាមិនកើតជាបញ្ហាចោទនោះទេ តែនៅក្នុងករណីកូនចៅមិនសប្បាយចិត្តទៅនឹងទ្រព្យ ដែលទទួល បញ្ហានឹងត្រូវបានកើតឡើងពោលគឺការបែងចែកនឹងត្រូវបានដោះស្រាយដោយច្បាប់នៅតុលាការ។ ទោះបីជា

មានការអះអាងបញ្ជាក់ឡើងពីឆន្ទៈពិតប្រាកដរបស់មតកជន ដោយសាក្សីក៏ច្បាប់មិនទទួលស្គាល់បណ្តាំដោយផ្ទាល់មាត់នេះដែរ។ ជាឧទាហរណ៍ ករណីជាក់ស្តែងរឿងក្តីរបស់ស្ត្រីម្នាក់រស់នៅខណ្ឌពោធិ៍សែនជ័យ បានលើកឡើងថា ប្តីរបស់គាត់ដែលជាមតកជន មុនទទួលមរណភាពបានហៅគាត់ និងកូន ព្រមទាំងកូនប្រសារ ដើម្បីនិយាយផ្តែផ្តាំ និងបែងចែកមត៌កដែលគាត់ មិនបានធ្វើឡើងដោយក្រដាសស្នាមនោះទេក៏ត្រូវបានសាលាដំបូងភ្នំពេញសម្រេចបែងចែកតាមច្បាប់ដោយមិនទទួលស្គាល់បណ្តាំមត៌កតាមរយៈការផ្តែផ្តាំផ្ទាល់មាត់របស់មតកជន។[៩១]

ទោះបីជាបណ្តាំមត៌កធ្វើឡើងជាលាយលក្ខណ៍អក្សរក៏ដោយ ការធ្វើឡើងតៗគ្នា ពីសម័យមុនបានធ្វើឱ្យប៉ះពាល់ដល់ផ្នត់គំនិតរបស់ប្រជាជនក្នុងការតាក់តែងមតកសាសន៍ផងដែរ។ ការតាក់តែងបណ្តាំមត៌កនៅសម័យបុរាណគឺគេមិនសូវខ្វល់ខ្វាយ ពីលក្ខខណ្ឌអ្វីទេឱ្យតែមានការសរសេរចែងទុកឱ្យកូនចៅជំនាន់ក្រោយនោះនឹងអាចយកមកអនុវត្តបាន។ ជាក់ស្តែងប្រជាពលរដ្ឋមិនសូវមានការខ្វល់ខ្វាយ និងយល់ដឹងច្បាស់អំពីមតកសាសន៍នោះទេ ផ្នត់គំនិតគឺពេលដែលទទួលមរណភាពទ្រព្យសម្បត្តិទាំងឡាយនឹងត្រូវបែងចែកឱ្យកូនចៅដោយស្វ័យប្រវត្តិ។ ហើយគោលគំនិតនេះបានចាក់ឫសគុលយ៉ាងជ្រៅនៅក្នុងផ្នត់គំនិតរបស់ប្រជាពលរដ្ឋកម្ពុជា។ មួយវិញទៀតប្រជាពលរដ្ឋភាគច្រើនមិនទាន់មានជីវភាពគ្រប់គ្រាន់ក្នុងការរស់នៅនូវឡើយ ជាហេតុធ្វើឱ្យគាត់ខិតខំប្រឹងប្រែងរកស៊ីដើម្បីចិញ្ចឹមជីវិតមិនបានគិតទៅដល់អនាគតកាល ដូចជាការសរសេរបណ្តាំមត៌កទុកឱ្យកូនចៅនោះទេ។ ដូច្នេះទើបមតកសាសន៍នៅប្រទេសកម្ពុជាមិនទាន់ដើរតួនាទីសំខាន់សម្រាប់ប្រជាពលរដ្ឋខ្មែរនៅឡើយ។ អាចដើរតួនាទីសំខាន់ចំពោះតែបុគ្គលមួយផ្នែកតូចមានជីវភាពធូរធារ ទ្រព្យសម្បត្តិច្រើន មានគំនិតគិតដិតដល់ទៅអនាគត និងមានឆន្ទៈក្នុងការបែងចែកទ្រព្យទៅឱ្យសន្តតិជន នៅពេលដែលទទួលមរណភាព។ ចំពោះប្រជាជនមួយចំនួនធំគឺខ្វាយខ្វល់តែអំពីការចិញ្ចឹមជីវិតរស់នៅបច្ចុប្បន្នភាពតែប៉ុណ្ណោះដោយសារ ជីវភាពខ្វះខាត និងមិនមានទ្រព្យសម្បត្តិណាមួយបន្សល់ទុកឱ្យកូនចៅជំនាន់ក្រោយ។ ដូច្នេះគោលគំនិតនេះបានបន្សល់ទុកធ្វើឱ្យមតកសាសន៍ប្រព្រឹត្តទៅដោយល្បឿនយឺត និងមិនមានប្រសិទ្ធិភាពខ្លាំងក្លាចំពោះប្រជាពលរដ្ឋដែលរស់នៅក្នុងសង្គមបច្ចុប្បន្ន។ ជាក់ស្តែងអ្នកវិជ្ជាជីវៈច្បាប់ដែលមានចំណេះដឹងនិងយល់ពីការបង្កើតមតកសាសន៍មានច្រើនប៉ុន្តែរាល់ការផ្តល់សេវាប្រឹក្សាយោបល់ ត្រូវគិតកម្រៃក្នុងការជួយតាក់តែង។ ទោះបីជាប្រទេសកម្ពុជាមានការរីកចម្រើនគួរឱ្យកត់សម្គាល់ ផ្នត់គំនិតបុរាណដែលបន្សល់ទុកស្តីការបែងចែកមត៌ក និងទម្រង់មតកសាសន៍នៅតែធ្វើឱ្យការអនុវត្តនាពេលបច្ចុប្បន្ន ប្រព្រឹត្តទៅយ៉ាងរអាក់រអួល។ ពេលខ្លះទោះជាចិត្តគំនិតអាចសម្របតាមការវិវត្តនៃការបែងចែក ការបន្តអនុវត្តសកម្មភាពតាមទំនៀមទម្លាប់ប្រពៃណីជាកត្តាជះឥទ្ធិពលខ្លាំង និងបញ្ហាប្រឈមផងដែរ ដែលនឹងពិភាក្សានៅចំណុចបន្ទាប់ (៣.៣)។

[៩១] កោះសន្តិភាព, "មុខស្លាប់ហៅផ្តែផ្តាំប្រគល់មត៌កហើយ... ផ្ទុះកំហឹងពេលតុលាការបែងចែកខុស," ១៥ មិថុនា ២០១៩, https://kohsantepheapdaily.com.kh/article/865644.html (ទស្សនាចុងក្រោយ ១៩ សីហា ២០២៤)។

## ៣.៣ ការបន្តអនុវត្តមតកសាសន៍តាមទម្លាប់

ប្រជាជនទាំងអស់មិនថាប្រុសស្រី មានទម្លាប់តាំងពីដើមមកគឺពេលធ្វើលិខិតស្នាមអ្វីមួយជាទូទៅត្រូវផ្ដិតម្រាមដៃ។ ទំនៀមទម្លាប់នេះបានចាក់ឫសយ៉ាងជ្រៅមិនអាចកែតម្រូវក្នុងរយៈពេលខ្លីបាន។ ដោយសារគិតថាស្នាមម្រាមដៃ សបញ្ជាក់ពីភាពច្បាស់លាស់ក្នុងការព្រមព្រៀងឬយល់ព្រមណាមួយ ដែលភាគីដទៃមិនអាចធ្វើការក្លែងបន្លំបាន។ លិខិតបទដ្ឋានគតិយុត្ត ភាគច្រើនមិនបានហាមប្រាម ឬដាក់លក្ខខណ្ឌណាមួយទៅភាគី អំពីការផ្ដិតម្រាមដៃ ឬចុះហត្ថលេខានោះទេ។ ប៉ុន្តែចំពោះការបង្កើតមតកសាសន៍វិញ ច្បាប់តម្រូវភាគីដែលបង្កើតមតកសាសន៍ត្រូវចុះហត្ថលេខានៅលើបណ្ដាំមត៌កជាដាច់ខាត និងជាលក្ខខណ្ឌចាំបាច់ផងដែរដើម្បីឱ្យមតកសាសន៍មានសុពលភាព។ ក្នុងនោះប្រភេទមតកសាសន៍ដែលធ្វើឡើងដោយលិខិតយថាភូត និងលិខិតសម្ងាត់ មិនសូវជាមានបញ្ហាប្រឈមនោះទេដោយសារនៅក្នុងនីតិវិធី នៃការបង្កើតមតកសាសន៍ទម្រង់ពីរប្រភេទនេះជានិច្ចកាលតែងតែមានអ្នកជំនាញនៅពីក្រោយចាំជួយផ្ដល់យោបល់និងតាក់តែង ដោយសារមតកសាសន៍ដោយលិខិតយថាភូត គឺតម្រូវធ្វើឡើងដោយសារការី[92] ហើយមតកសាសន៍ដោយលិខិតសម្ងាត់ ច្បាប់ក៏មិនបានហាមឃាត់មតកជនក្នុងការស្នើសុំពីអ្នកជំនាញណាមួយឡើយ ពោលគឺអាចមានការធ្វើ ឬប្រឹក្សាយោបល់ពីអ្នកវិជ្ជាជីវៈណាមួយបាន។[93] ចំណុចដែលមានការព្រួយបារម្ភខ្លាំងនោះគឺការបង្កើតមតកសាសន៍ដោយលិខិតឯកជន ដោយសារតែមតកសាសន៍ប្រភេទនេះ បានកើតឡើងជាយូរណាស់មកហើយតាំងពីបុរាណកាលមកដោយមនុស្សជំនាន់មុនសរសេរបណ្ដាំមត៌កទៅមនុស្សជំនាន់ក្រោយដោយក្រដាសហើយទុកកន្លែងណាមួយដែលមានសុវត្ថិភាព។

មតកសាសន៍ដោយលិខិតឯកជន មានភាពងាយស្រួលច្រើនក្នុងការតាក់តែងបើប្រៀបទៅនឹងពីរប្រភេទផ្សេងទៀតដែលពិភាក្សានៅខាងលើ។ ដោយសារតែមតកសាសន៍ប្រភេទនេះ តម្រូវឱ្យមតកជនចុះហត្ថលេខានៅលើមតកសាសន៍ដើម្បីឱ្យមានសុពលភាពអាចអនុវត្តបាន។[94] ការយល់ដឹងរបស់ប្រជាជនមានការខ្វះចន្លោះដោយសារការអនុវត្តជាប្រចាំ គឺការផ្ដិតស្នាមម្រាមដៃបញ្ជាក់ពីភាពច្បាស់លាស់ មិនមែនជាការចុះហត្ថលេខាដែលនាំឱ្យការបង្កើតមតកសាសន៍នានា ក្លាយជាអសុពលភាពមិនអាចអនុវត្តបានតាមឆន្ទៈរបស់មតកជននៅពេលទទួលមរណភាព។ ចំណុចផលវិបាកនេះកើតឡើងជាបញ្ហាប្រឈមខ្លាំងសម្រាប់សង្គមខ្មែរបច្ចុប្បន្ន ដោយសារតែក្រមរដ្ឋប្បវេណីប្រទេសកម្ពុជា មានការជំនួយក្នុងការតាក់តែងពីប្រទេសជប៉ុន ដែលជាប្រទេសរីកចម្រើន ក្នុងនោះឃើញថា ប្រទេសជប៉ុនមានប្រជាជនភាគច្រើនប្រើប្រាស់របៀបនៃការចុះហត្ថលេខា ប៉ុន្តែការចុះហត្ថលេខារបស់ប្រជាជនប្រទេសជប៉ុនគឺជាការបោះត្រាហត្ថលេខាដោយគ្រាន់តែផ្ដិតនៅលើក្រដាសគឺសម្គាល់ជាហត្ថលេខាផ្លូវ

[92] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា១១៧៣។

[93] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា១១៧៥។

[94] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា១១៧៤(១)។

ការហើយ។[95] សង្គមខ្មែរបច្ចុប្បន្នពុំទាន់ដើរដល់ចំណុចមួយដែលប្រជាពលរដ្ឋយល់ដឹងផ្នែកច្បាប់ច្រើននោះទេដែលធ្វើឱ្យមានផលវិបាកកើតឡើង និងមានភាពអយុត្តិធម៌ទៅលើបុគ្គលទាំងនោះដែលមិនអាចសម្រេចបាននូវអ្វីដែលខ្លួនសរសេរនៅក្នុងមតកសាសន៍។

[95] Hanko/Inkan, A Guide to the World of Japanese Signature Seals. https://www.japanlivingguide.com/living-in-japan/culture/hanko-inkan/ (ទស្សនាចុងក្រោយ ៥ សីហា ២០២៤) ។

# សេចក្តីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

សន្តតិកម្មតាមមតកសាសន៍ គឺជាជម្រើសដ៏ល្អមួយដែលផ្តល់សិទ្ធិឱ្យមតកជនបែងចែកទ្រព្យរបស់ខ្លួនទៅឱ្យសន្តតិជនតាមឆន្ទៈប្រកបដោយសមធម៌។ របបសន្តតិកម្មនៅកម្ពុជាបានឆ្លងកាត់ការគ្រប់គ្រងដោយវិធានគតិយុត្តជាច្រើនមុននឹងមានវត្តមានក្រមរដ្ឋប្បវេណីឆ្នាំ២០០៧។ ការបែងចែកមត៌កបានផ្តល់នូវសិទ្ធិពេញលេញដល់ជនទាំងឡាយក្នុងការប្រគល់បែងចែកទ្រព្យសម្បត្តិណាមួយឱ្យទៅបុគ្គលណាម្នាក់រួមមានសន្តតិជន ឬតតិយជនតាមការបង្ហាញឆន្ទៈរបស់ខ្លួន។ ជាក់ស្តែងការបង្កើតបណ្តាំមត៌កនេះគឺជាវិធីសាស្ត្រមួយដ៏ល្អប្រសើរ និងច្រើនជម្រើសនិងផ្តល់នូវពេលវេលាសមរម្យជូនដល់មតកជនក្នុងការគិតពិចារណាប្រគល់ទ្រព្យដែលជាមត៌កដល់សន្តតិជនឬបុគ្គលណាមួយនៅពេលមតកជនទទួលមរណភាព។

ទន្ទឹមនឹងការប្រសើរឡើងនូវវិធានគតិយុត្ត ដែលគ្រប់គ្រងសកម្មភាពនានាទាក់ទងនឹងការបែងចែកមត៌ក និងការកំណត់នូវលក្ខខណ្ឌផ្សេងៗដើម្បីបង្កើតបាននូវមតកសាសន៍មួយមានសុពលភាព ការអនុវត្តប្រចាំថ្ងៃនៅតែជាបញ្ហាស្មុគស្មាញក្នុងការបែងចែកមត៌កក្នុងសង្គមខ្មែរបច្ចុប្បន្ននៅឡើយ។ បញ្ហាទាំងនេះបង្កើតបានជាផលវិបាកជាច្រើន ដោយក្នុងនោះមតកសាសន៍ដែលខុសទម្រង់គឺជា បញ្ហាមួយដែលឃើញមានវត្តមានជាញឹកញាប់នៅក្នុងសង្គមដោយសារតែការអនុវត្តតាមប្រពៃណីពីមួយជំនាន់ទៅមួយជំនាន់បន្សល់ទុកពីបុរាណកាលមក។ មិនតែប៉ុណ្ណោះការបង្កើតមតកសាសន៍ជាច្រើន ទោះបីធ្វើឡើងត្រឹមត្រូវតាមទម្រង់ពិតមែនប៉ុន្តែធ្វើឡើងដោយប៉ះពាល់ដល់ផលប្រយោជន៍សន្តតិជន ដោយការផ្តល់ឬបែងចែកមត៌កទៅឱ្យសន្តតិជនណាម្នាក់ច្រើនលើសលប់ ឬពេលខ្លះបែងចែកទ្រព្យដែលជាមត៌កទៅឱ្យតតិយជនក្រៅពីសន្តតិជន ជាហេតុធ្វើឱ្យមានការរំលោភលើភាគបម្រុងដល់សន្តតិជនដទៃ។ ការអនុវត្តពីបុគ្គលពាក់ព័ន្ធក៏ជាហេតុផលមួយប៉ះពាល់ដល់ការអនុវត្ត និងជាបញ្ហាស្មុគស្មាញផងដែរ។ ទោះបីជាមតកសាសន៍បង្កើតឡើងដោយត្រឹមត្រូវតាមច្បាប់កំណត់ ក៏បញ្ហាផ្សេងៗនៅតែបន្តកើតឡើងដោយសារភាគីដែលពាក់ព័ន្ធ។ ជាការពិតណាស់ការយល់ដឹងរបស់ប្រជាពលរដ្ឋទាក់ទងទៅនឹងសន្តតិកម្មនៅមានកម្រិត ជាហេតុមានវត្តមានអ្នកវិជ្ជាជីវៈផ្សេងៗ ប៉ុន្តែសកម្មភាពរបស់អ្នកវិជ្ជាជីវៈទាំងនោះហាក់ដូចជាមានការឆ្កៀតឆ្កងដោយធ្វើឡើងផ្ទុយពីច្បាប់និងខ្លះទៀតធ្វើសកម្មភាពដែលច្បាប់មិនអនុញ្ញាត ធ្វើឱ្យការអនុវត្តផ្ទុយពីឆន្ទៈពិតរបស់មតកជន និងឈានដល់បាត់បង់ផលប្រយោជន៍របស់សន្តតិជន។ ជាពិសេសករណីទ្រព្យមត៌កជាអចលនវត្ថុដែលបន្ទុកនៃការដើរនីតិវិធីធ្លាក់ទៅលើមន្ត្រីសុរិយោដី ហើយភាពអសកម្មនិងភាពមិនគោរពតាមវិជ្ជាជីវៈ អាចបង្កើតបានជាបញ្ហាមួយផ្នែកផងដែរ។ ការអូសបន្លាយពេលវេលាដោយសារអសកម្ម ឬការចង់បានផលប្រយោជន៍ផ្សេងៗពីភាគីដែលចុះបញ្ជីជាថ្នូរដើម្បីពន្លឿននីតិវិធីគឺជាប្រធានបទមួយដែលមានភាពស្មុគស្មាញនិងកើតជាផលវិបាកព្រួយបារម្ភណ៍ដល់សន្តតិជនផងដែរ។ ការដោះស្រាយតាមប្រព័ន្ធតុលាការនៅតែជានីតិវិធីមួយក្នុងការសម្រេចសេចក្តីអំពីការបែងចែកមត៌កទោះបីជាមានវត្តមានមតកសាសន៍ក៏ដោយ។ នៅពេលដែលមតកសាសន៍ខុសទម្រង់ ឬការចែងទ្រព្យនានានៅក្នុងមតកសាសន៍ខ្វះទៅនឹងទ្រព្យដែលមតកជនមានជាក់ស្តែងនោះការបែងចែកនៅតែធ្វើឡើងដោយតុលាការ ដូច្នេះការ

សម្រេចសេចក្តីក៏ជាផ្នែកមួយនៃការព្រួយបារម្ភណ៍ផងដែរដោយសារការប្រើប្រាស់មនោសញ្ចេតនាពីសំណាក់អ្នកសម្រេចសេចក្តី។

ទោះបីកម្ពុជាមានច្បាប់ចែងយ៉ាងលំអិតអំពីរបបសន្តតិកម្ម ការខ្វះការយល់ដឹងរបស់ប្រជាជនអំពីការបែងចែកមត៌កតាមមតកសាសន៍នូវតែជាបញ្ហាចោទនៅក្នុងសង្គមខ្មែរនៅឡើយ។ ប្រជាជនភាគច្រើនបន្តអនុវត្តមតកសាសន៍តាមទម្លាប់ប្រពៃណី ជាហេតុធ្វើឱ្យមិនអាចអនុវត្តតាមអ្វីដែលបានបង្កើតនិងសរសេរនៅក្នុងមតកសាសន៍នោះដោយសារតែខុសទម្រង់ដែលជាលក្ខខណ្ឌចាំបាច់តម្រូវដោយច្បាប់។ ការបែងចែកមត៌កតាមមតកសាសន៍នេះទៀតសោត ធ្វើឡើងក្រៅតុលាការ ឬធ្វើនៅតុលាការតាមប្រភេទនៃមតកសាសន៍របស់មតកជនបង្កើត ។ ការធ្វើមតកសាសន៍នេះមានផលប្រយោជន៍ច្រើន ជាជម្រើសដល់មតកជននៅក្នុងការចែកមត៌កទៅបុគ្គលណាម្នាក់ដែលជាសន្តតិជន ឬអាចប្រគល់បុគ្គលណាម្នាក់ដែលម្ចាស់មតកសាសន៍ចង់ដែលជា ជម្រើសបន្ថែមដល់មតកជន។ ទោះបីជាសន្តតិកម្មតាមមតកសាសន៍ផ្តល់ផលប្រយោជន៍ច្រើនដល់ សន្តតិជនដែលជាទទួលការស្នងមត៌ក និងភាពងាយស្រួលដល់មតកជនក្នុងការបង្កើតមតកសាសន៍តាមឆន្ទៈរបស់ខ្លួន បញ្ហាតែងតែលេចឡើងឱ្យឃើញតាមរយៈការបង្កើតមតកសាសន៍ដោយខុសទម្រង់ ជាហេតុធ្វើឱ្យមិនអាចអនុវត្តបានតាមមតកសាសន៍ និងផ្លាស់ប្តូរមកបែងចែកតាមច្បាប់វិញផ្ទុយទៅនឹងឆន្ទៈ របស់មតកជន។

# អនុសាសន៍

# អនុសាសន៍

ក្រសួងយុត្តិធម៌ គួរតែបន្ថែមនូវការផ្សព្វផ្សាយឱ្យបានទូលំទូលាយអំពីចំណេះដឹងទូទៅទាក់ទងនឹងសន្តតិកម្មតាមមតកសាសន៍ដល់ប្រជាពលរដ្ឋ និងស្ថាប័នដែលពាក់ព័ន្ធមួយចំនួនដូចជា ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា អំពីការបង្កើតមតកសាសន៍មួយដែលត្រឹមត្រូវអាចអនុវត្តបាន។វគ្គបណ្តុះបណ្តាល និងសិក្ខាសាលាគប្បីធ្វើឡើងឱ្យបានទៀងទាត់ជូនដល់ភាគីដែលពាក់ព័ន្ធ។ លើសពីនេះការផ្សព្វផ្សាយអាចធ្វើតាមរយៈការបង្ហោះទៅតាមរយៈបណ្តាញសង្គមផ្សេងៗ អាចជួយប្រជាជនដែលមានចំណាប់អារម្មណ៍អាចតាមដាន។ ការផ្សព្វផ្សាយតាមរយៈបណ្តាញសង្គមគឺជាមធ្យោបាយផ្សព្វផ្សាយមួយដ៏មានប្រសិទ្ធភាពខ្ពស់។[96]

គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា គួរមានការរឹតបន្តឹងដល់អ្នកវិជ្ជាជីវៈទាំងឡាយ និងបុគ្គលពាក់ព័ន្ធផ្សេងទៀតឱ្យមានភាពយល់ដឹងកាន់តែច្បាស់លាស់លើការបង្កើតមតកសាសន៍គ្រប់ប្រភេទ និងទម្រង់មុននឹងមានឈានដល់ការប្រឹក្សាផ្តល់យោបល់ជូនទៅអតិថិជនឬបុគ្គលដែលមានតម្រូវការ ដើម្បីបញ្ចៀសនូវកំហុសណាមួយធ្វើឱ្យបាត់បង់សុពលភាពនៃមតកសាសន៍។ ការរឹតបន្តឹង និងតាមដានសកម្មភាពរបស់អ្នកវិជ្ជាជីវៈអាចធ្វើតាមរយៈសិក្ខាសាលា ឬកិច្ចពិភាក្សាផ្សេងៗ ដើម្បីធានាបាននូវគុណភាពច្បាស់មុនពេលផ្តល់យោបល់ជូនទៅអ្នកមានតម្រូវការ ឬអតិថិជន។

ក្រសួងយុត្តិធម៌ គួរតែធ្វើការកែតម្រូវលើបញ្ញត្តិស្តីពីលក្ខខណ្ឌទម្រង់ក្នុងការបង្កើតមតកសាសន៍លើប្រភេទមតកសាសន៍នីមួយៗជាពិសេសមតកសាសន៍តាមលិខិតឯកជន។ រាល់ទម្រង់ដែលជាលក្ខខណ្ឌចាំបាច់ដើម្បីធ្វើឱ្យមតកសាសន៍មានសុពលភាព គួរតែមានការកែតម្រូវឱ្យស្របទៅនឹងការយល់ដឹងរបស់ប្រជាពលរដ្ឋត្រង់ចំណុច លក្ខខណ្ឌឱ្យមតកជនធ្វើការចុះហត្ថលេខា មកទទួលយកការផ្តិតស្នាមម្រាមដៃវិញ។ ដោយហេតុថាប្រទេសកម្ពុជាគឺជាប្រទេសកំពុងអភិវឌ្ឍ ប្រជាជនខ្វះការយល់ដឹងនៅមានវត្តមានច្រើន ជាពិសេសប្រជាពលរដ្ឋដែលមិនចេះអក្សរ[97] ពេលខ្លះសឹងតែរបៀបក្នុងការកាន់ប៊ិកក៏មិនចេះផង តើអាចឱ្យចុះហត្ថលេខាបានយ៉ាងដូចម្តេច? ចំណុចនេះគឺជាបញ្ហាគួរឱ្យព្រួយបារម្ភនិងមានភាពមិនស៊ីសង្វាក់ទៅនឹងស្តង់ដារស់នៅរបស់ប្រជាជនខ្មែរ។ ក្រសួងយុត្តិធម៌គួរតែកែសម្រួលឱ្យមានភាពងាយស្រួលដល់មតកជនក្នុងការបង្កើតមតកសាសន៍ និងដាក់លក្ខខណ្ឌងាយស្រួលជាងនេះដល់ប្រជាជនដូចជាផ្លាស់ប្តូរពីការចុះហត្ថលេខាលើមតកសាសន៍មកផ្តិតស្នាម

[96] ណោង សុខនិមល, "តើគួរប្រើប្រព័ន្ធផ្សព្វផ្សាយសង្គមរបៀបណាដើម្បីបង្កើតឥទ្ធិពលវិជ្ជសម្រាប់សង្គម," AMS, ២១ សីហា ២០២៣។

[97] VOA, "កម្ពុជានៅតែប្រឈមនឹងអត្រាអនក្ខរភាពខ្ពស់," ២៦ សីហា ២០១១, https://khmer.voanews.com/a/cambodia-facing-ongoing-literacy-challenges-128491993/1143285.html (ទស្សនាចុងក្រោយ ២៨ សីហា ២០២៤)។

ម្រាមដៃវិញ[98]ឬអាចមានជម្រើសពីរដោយផ្តិតស្នាមម្រាមដៃ ក៏បានចុះហត្ថលេខាក៏បានដោយសារការចុះហត្ថលេខាក៏មានសារៈសំខាន់ក្នុងកាលៈទេសៈខ្លះផងដែរ។[99]

[98] Kensington, "Advantages of Biometrics: Why Fingerprint Scanners Are the Future of Security," https://www.kensington.com/news/security-blog/biometric-authentication-overview-of-the-advantages-and-benefits/ (ទស្សនាចុងក្រោយ ២៩ សីហា ២០២៤) ។

[99] Marcus Smith, "The Rise of Biometric Identification: Fingerprints and Applied Ethics.

https://link.springer.com/chapter/10.1007/978-3-030-90256-8_1 (ទស្សនាចុងក្រោយ ២៩ សីហា ២០២៤) ។

# គន្ថនិទ្ទេស


## ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា

ច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី, លេខ នស/រកប/០៥១១/00៧, ៣១ ឧសភា ២០១១។

ច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីមិនមែនបណ្តឹង, លេខ នស/រកម/0៧0១/0១៣, ១0 កក្កដា ២0១0។

ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២0៧/0៣0, 0៨ ធ្នូ ២00៧។

ច្បាប់ភូមិបាល, លេខ នស/រកម/0៨0១/១៤, ៣0 សីហា ២00១។

ក្រមរដ្ឋប្បវេណីកម្ពុជាឆ្នាំ១៩២០។

ប្រកាសអន្តរក្រសួងរបស់ក្រសួងយុត្តិធម៌ និងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ស្តីពីនីតិវិធីនៃការចុះបញ្ជីអំពីសិទ្ធិប្រត្យក្សទាក់ទងនឹងក្រមរដ្ឋប្បវេណី, លេខ៣0អយដនស/ប្រក/១៣, ២៩ មករា ២០១៣។

## សាលក្រម

សាលក្រមសាលាដំបូងរាជធានីភ្នំពេញ, លេខ១០៨ <<ភ>>ជ.រ, ១៩ មីនា ២០១៩។

## សៀវភៅ និងឯកសារផ្សេងៗ

កើត រិទ្ធ, ចាំង ស៊ីណាត, កាន ច័ន្ទមេត្តា, ថេង ច័ន្ទសង្វារ, បេអាទ្រីស បាលីវេ និងឡូអ៊ីក អារីឡាណឺដា. *សេចក្តីផ្តើមនៃនីតិកម្ពុជា.* ការិយាល័យស្រាវជ្រាវនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច ភ្នំពេញ, ២០០៥។

គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា. ព្រឹត្តិបត្រមេធាវី, លេខ១៣ (២០១៧)។

ទេព បូផល. "សន្តតិកម្មតាមមតកសាសន៍." ឯកសារថតចម្លង, ១១ មិថុនា ២០២៣។

ជួន ណាត. *វចនានុក្រមខ្មែរ.* ភ្នំពេញ៖ ពុទ្ធសាសនបណ្ឌិត្យ, ១៩៦៨។

វ៉ី ភីរក្ស. "អច្ច័យទាន." ឯកសារថតចម្លង, ២០២៣។

ស៊ិន ច័ន្ទផល្គុន. "ភាគបម្រុង." ឯកសារថតចម្លង, ៩ កក្កដា ២០២៣។

__________. "សន្តតិកម្ម គោលការណ៍ទូទៅ." វគ្គបណ្តុះបណ្តាលក្រមរដ្ឋប្បវេណី វគ្គ៥, ២០២៣។

ហាប់ ផល្លី. *នីតិទ្រព្យសម្បត្តិឯកជន៖ ករណីសិក្សានៅកម្ពុជា.* ភ្នំពេញ៖ Premium Advertising, ២០២១។

_________. *វិធីសាស្ត្រស្រាវជ្រាវ និងការសរសេរបែបសិក្សា.* បោះពុម្ពលើកទី៣. ភ្នំពេញ៖ Premium Advertising, ២០២១។

អាដេម៉ារ ឡឺក្លែរ. *មជ្ឈមណ្ឌលឯកសារកម្ពុជា ប្រវត្តិសាស្ត្រប្រទេសកម្ពុជា ចាប់តាំងពីសតវត្សរ៍ទី១ នៃគ្រិស្តសករាជរហូតមក.* ភ្នំពេញ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា។

## **ការសែត ពីគេហទំព័រ**

FBR Plus News. "លោកជំទាវ ពេជ ម៉ារ៉ែន ប្រធានសាលាដំបូងខេត្តតាកែវ សម្របសម្រួលផ្សះផ្សាបញ្ចប់វិវាទករណីប្តឹងសុំបែងចែកមត៌ក ប្រកបដោយជោគជ័យ." ៧ សីហា ២០២៤។

Hanko/Inkan. "A Guide to the World of Japanese Signature Seals." [មគ្គុទ្ទេសទៅកាន់ពិភពនៃត្រាហត្ថលេខាប្រទេសជប៉ុន]. https://www.japanlivingguide.com/living-in-japan/culture/hanko-inkan/ (ទស្សនាចុងក្រោយ ៥ សីហា ២០២៤) ។

VOA. "កម្ពុជានៅតែប្រឈមនឹងអត្រាអនក្ខរភាពខ្ពស់." ២៦ សីហា ២០១១. https://khmer.voanews.com/a/cambodia-facing-ongoing-literacy-challenges-128491993/1143285.html (ទស្សនាចុងក្រោយ ២៨ សីហា ២០២៤) ។

Wistrich, Andrew J., Rachlinski, Jeffrey J. និង Chris, Guthrie. "Heart Versus Head; Do judges Follow the Law or follow their feeling?." [បេះដូង និងខួរក្បាល; តើចៅក្រមអនុវត្តតាមច្បាប់ ឬធ្វើតាមអារម្មណ៍របស់ពួកគេ?]. https://texaslawreview.org/wp-content/uploads/2015/08/Rachlinski-93-4.pdf (ទស្សនាចុងក្រោយ ១៩ សីហា ២០២៤) ។

Kensington. "Advantages of Biometrics: Why Fingerprint Scanners Are the Future of Security."[ហេតុអ្វីបានជាម៉ាស៊ីនស្កេនស្នាមម្រាមដៃគឺជាអនាគតនៃសន្តិសុខ]. https://www.kensington.com/news/security-blog/biometric-authentication-overview-of-the-advantages-and-benefits/ (ទស្សនាចុងក្រោយ ២៩ សីហា ២០២៤) ។

Smith, Marcus. "The Rise of Biometric Identification: Fingerprints and Applied Ethics." [ការកើនឡើងនៃការកំណត់អត្តសញ្ញាណជីវមាត្រ៖ស្នាមម្រាមដៃនិងក្រមសីលធម៌អនុវត្ត]. https://link.springer.com/chapter/10.1007/978-3-030-90256-8_1 (ទស្សនាចុងក្រោយ ២៩សីហា ២០២៤) ។

កោះសន្តិភាព. "មុខស្លាប់ហៅផ្តៃផ្គាំប្រគល់មត៌កហើយ... ផ្ទុះកំហឹងពេលតុលាការបែងចែកខុស." ១៥ មិថុនា ២០១៩. https://kohsantepheapdaily.com.kh/article/865644.html (ទស្សនាចុងក្រោយ ១៥ សីហា ២០២៤) ។

ណោង សុខនិមល. "តើគួរប្រើប្រព័ន្ធផ្សព្វផ្សាយសង្គមរបៀបណាដើម្បីបង្កើតឥទ្ធិពលវិជ្ជសម្រាប់សង្គម." AMS." ២១ សីហា ២០២៣. https://education.ams.com.kh/life-education/news/using-social-media-to-create-a-positive-impact-in-your-society (ទស្សនាចុងក្រោយ ២៨ សីហា ២០២៤) ។

ទ្រី វ៉ារី. "ទីបំផុតរឿងក្តីបណ្តាំមរតករបស់គ្រួសារ ស៊ូ ស៊ីរីកា និងជុំ រស្មី ឈានដល់ទីបញ្ចប់ដោយសន្តិវិធី." https://infotainment.ams.com.kh/celebrity/news/finally-the-case-of-sou-sirika-and-chum-raksmey-inheritance-came-to-a-peaceful-end/ (ទស្សនាចុងក្រោយ ១៥ សីហា ២០២៤) ។

ម៉ែន សំអន. "វេទិកាផ្សព្វផ្សាយយេនឌ័រ." មជ្ឈមណ្ឌលកោះពេជ្រភ្នំពេញ ៩ កុម្ភៈ ឆ្នាំ២០២០. https:/www.cpp.org.kh/details/181684 (ទស្សនាចុងក្រោយ ១២ សីហា ២០២៤) ។